ក N°19/16→12/03/2016

# មាតិកា

## I~ព្រះរាជខុទ្ទកាល័យព្រះមហាក្សត្រ

### ព្រះរាជក្រឹត្យ


១២-០២-២០១៦ -ព្រះរាជក្រឹត្យ នស/រកត/០២១៦/២០២ ស្តីពី ការផ្តល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្ម ដល់កញ្ញា **វឌ្ឍចាណាផុកា អនឈុម៉ា** (VATJANAPUKKA ORNCHUMA) ជនជាតិ ថៃ សញ្ជាតិថៃ ២១២១

១២-០២-២០១៦ -ព្រះរាជក្រឹត្យ នស/រកត/០២១៦/២០៣ ស្តីពី ការផ្តល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្ម ដល់លោក **ស៊ូ ជឺឈីង** (SU ZIQING) ជនជាតិចិន សញ្ជាតិចិន ២១២២

១២-០២-២០១៦ -ព្រះរាជក្រឹត្យ នស/រកត/០២១៦/២០៤ ស្តីពី ការផ្តល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្ម ដល់លោក **ចាង គួតុង** (ZHANG GUODONG) ជនជាតិចិន សញ្ជាតិចិន ២១២៣

១២-០២-២០១៦ -ព្រះរាជក្រឹត្យ នស/រកត/០២១៦/២០៥ ស្តីពី ការផ្តល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្ម ដល់លោក **ចូវ ជិងឈិន** (ZHOU JINCHENG) ជនជាតិចិន សញ្ជាតិចិន ២១២៤

១៨-០២-២០១៦ -ព្រះរាជក្រឹត្យ នស/រកត/០២១៦/២០៧ ស្តីពី ការតែងតាំងមុខតំណែង និងផ្តល់ឋានៈ លោកជំទាវ **សែង លីណា** ជាទីប្រឹក្សាក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និង អធិការកិច្ច មានឋានៈស្មើ អគ្គនាយក ២១២៥

១៨-០២-២០១៦ -ព្រះរាជក្រឹត្យ នស/រកត/០២១៦/២០៨ ស្តីពី ការតែងតាំង និងផ្តល់ឋានៈ ជាទីប្រឹក្សា សម្តេចក្រឡាហោម **ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ចំនួន ០២ រូប ២១២៦

១៨-០២-២០១៦ -ព្រះរាជក្រឹត្យ នស/រកត/០២១៦/២០៩ ស្តីពី ការផ្ទេរក្របខ័ណ្ឌលោក **យី តាលី** នៃ ក្របខ័ណ្ឌមន្ត្រីរដ្ឋបាលជាន់ខ្ពស់ក្រសួងមហាផ្ទៃ មកក្នុងក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា ក្រសួងមហាផ្ទៃ ២១២៧

១៨-០២-២០១៦ -ព្រះរាជក្រឹត្យ នស/រកត/០២១៦/២១០ ស្តីពី ការតម្លើងឋានន្តរស័ក្តិ ដល់នាយទាហាន ថ្នាក់ឧត្តមសេនីយ៍ និងថ្នាក់វរសេនីយ៍ នៃកងយោធពលខេមរភូមិន្ទ ចំនួន ៤៩ រូប ២១២៨

១៨-០២-២០១៦ -ព្រះរាជក្រឹត្យ នស/រកត/០២១៦/២១១ ស្តីពី ការតាំងស៊ប់ក្នុងក្របខ័ណ្ឌដល់មន្ត្រី រាជការ ៥២ រូប នៃក្របខ័ណ្ឌមន្ត្រីបច្ចេកទេសជាន់ខ្ពស់ របស់ក្រសួងការងារ និងបណ្តុះ បណ្តាលវិជ្ជាជីវៈ ២១៣០

១៨-០២-២០១៦ -ព្រះរាជក្រឹត្យ នស/រកត/០២១៦/២១២ ស្តីពី ការផ្តល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្ម ដល់លោក **លី វៃ ហ្វុង** (LI WAI FUNG) ជនជាតិចិន សញ្ជាតិចិន ២១៣៣

១៨-០២-២០១៦ -ព្រះរាជក្រឹត្យ នស/រកត/០២១៦/២១៣ ស្តីពី ការផ្តល់សញ្ជាតិខ្មែរ ដោយអាពាហ៍ពិពាហ៍ ដល់អ្នកស្រី **សិរិណាត ផល្លាបុត្រ** (SIRINARD PONLABUTE) ជនជាតិថៃ សញ្ជាតិថៃ ដោយប្តូរឈ្មោះជា **លឹម សិរិណាត** (LIM SIRINARD ) ២១៣៤

១៨-០២-២០១៦ -ព្រះរាជក្រឹត្យ នស/រកត/០២១៦/២១៤ ស្តីពី ការផ្តល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្ម ដល់អ្នកស្រី **អ៊ូ ជូលីង** (WU JUI-LING) ជនជាតិចិនតៃវ៉ាន់ សញ្ជាតិចិនតៃវ៉ាន់ ២១៣៥

## II~ក្រុមប្រឹក្សាធម្មនុញ្ញ

០៣-០៣-២០១៦ -សេចក្តីសម្រេចលេខ ១៥៩/០០១/២០១៦ កបធ.ច ចុះថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ២០១៦ លើសំណុំរឿង លេខ ២៦០/០០១/២០១៦ ចុះថ្ងៃទី ១០ ខែ កុម្ភៈ ឆ្នាំ ២០១៦ ២១៣៦

## III~រាជរដ្ឋាភិបាល

### ១~អនុក្រឹត្យ

១១-១២-២០១៥ -អនុក្រឹត្យលេខ ១៧១ អនក្រ.បក ស្តីពី ការដាក់ឱ្យអនុវត្តកម្មវិធីកាត់បន្ថយ និង/ឬ លុបបំបាត់ពន្ធគយរបស់ព្រះរាជាណាចក្រកម្ពុជា ស្របតាមនាមវលីនៃតារាងពន្ធគយសុខដុម របស់អាស៊ាន ឆ្នាំ ២០១២ ក្រោមកិច្ចព្រមព្រៀងពាណិជ្ជកម្មទំនិញអាស៊ាន

*(ត មកពី រាជកិច្ច លេខ ០១-១៨)* ២១៤២

០៣-០៣-២០១៦ -អនុក្រឹត្យលេខ ៣៣ អនក្រ.បក ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅនៃមូលនិធិជាតិ សម្រាប់ការប្រយុទ្ធប្រឆាំងគ្រឿងញៀន ២១៧១

០៤-០៣-២០១៦ -អនុក្រឹត្យលេខ ៣៤ អនក្រ.បក ស្តីពី ការកែសម្រួលតួនាទី និងភារកិច្ចរបស់ក្រសួង បរិស្ថាន និងរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ពាក់ព័ន្ធនឹងសមត្ថកិច្ច និងការគ្រប់គ្រងតំបន់វិនិយោគអភិវឌ្ឍន៍សម្បទានដីសេដ្ឋកិច្ច និងការគ្រប់គ្រងតំបន់ ការពារ និងអភិរក្សព្រៃឈើ និងជលផល ២១៧៦

០៤-០៣-២០១៦ -អនុក្រឹត្យលេខ ៣៥ អនក្រ.បក ស្តីពី ការកែសម្រួលអត្រាអាករនាំចេញលើមុខទំនិញកៅស៊ូ ២១៧៨

០៧-០៣-២០១៦ -អនុក្រឹត្យលេខ ៣៦ អនក្រ.បក ស្តីពី ការផ្ទេរភណ្ឌទានថវិកា ២១៨០

០៩-០៣-២០១៦ -អនុក្រឹត្យលេខ ៣៧ អនក្រ.បក ស្តីពី ការកែសម្រួល និងការដំឡើងប្រាក់បំណាច់ មុខងារ ជូនយោធិននៃកងយោធពលខេមរភូមិន្ទ ២១៨២

១១-០២-២០១៦ -អនុក្រឹត្យលេខ ១៥៧ អនក្រ.តត ស្តីពី ការជូនមេដាយស្ថាបនាជាតិ ២១៨៦
១១-០២-២០១៦ -អនុក្រឹត្យលេខ ១៥៨ អនក្រ.តត ស្តីពី ការជូនមេដាយការងារ ២១៨៨
១២-០២-២០១៦ -អនុក្រឹត្យលេខ ១៥៩ អនក្រ.តត ស្តីពី ការជូនមេដាយស្ថាបនាជាតិ ២១៩០
១២-០២-២០១៦ -អនុក្រឹត្យលេខ ១៦០ អនក្រ.តត ស្តីពី ការជូនមេដាយស្ថាបនាជាតិ ២១៩២
១២-០២-២០១៦ -អនុក្រឹត្យលេខ ១៦១ អនក្រ.តត ស្តីពី ការបញ្ចប់ភារកិច្ចមន្ត្រីរាជការ ២១៩៤
១៩-០២-២០១៦ -អនុក្រឹត្យលេខ ១៦២ អនក្រ.តត ស្តីពី ការជូនមេដាយមុនីសារាភ័ណ្ឌ ២១៩៥
១៩-០២-២០១៦ -អនុក្រឹត្យលេខ ១៦៣ អនក្រ.តត ស្តីពី ការជូនមេដាយការងារ ២១៩៧
១៩-០២-២០១៦ -អនុក្រឹត្យលេខ ១៦៤ អនក្រ.តត ស្តីពី ការជូនមេដាយស្ថាបនាជាតិ ២១៩៨
១៩-០២-២០១៦ -អនុក្រឹត្យលេខ ១៦៥ អនក្រ.តត ស្តីពី ការតែងតាំងមន្ត្រីរាជការ ២១៩៩
១៩-០២-២០១៦ -អនុក្រឹត្យលេខ ១៦៦ អនក្រ.តត ស្តីពី ការជូនមេដាយមុនីសារាភ័ណ្ឌ ២២០១
១៩-០២-២០១៦ -អនុក្រឹត្យលេខ ១៦៧ អនក្រ.តត ស្តីពី ការជូនមេដាយស្ថាបនាជាតិ ២២០២
១៩-០២-២០១៦ -អនុក្រឹត្យលេខ ១៦៨ អនក្រ.តត ស្តីពី ការផ្ទេរភារកិច្ច និងតែងតាំងមុខតំណែងមន្ត្រីនគរបាលជាតិកម្ពុជា ២២០៣
១៩-០២-២០១៦ -អនុក្រឹត្យលេខ ១៦៩ អនក្រ.តត ស្តីពី ការតែងតាំងមន្ត្រីរាជការ ២២០៤
១៩-០២-២០១៦ -អនុក្រឹត្យលេខ ១៧០ អនក្រ.តត ស្តីពី ការជូនមេដាយមុនីសារាភ័ណ្ឌ ២២០៥
១៩-០២-២០១៦ -អនុក្រឹត្យលេខ ១៧១ អនក្រ.តត ស្តីពី ការជូនមេដាយការងារ ២២០៦
១៩-០២-២០១៦ -អនុក្រឹត្យលេខ ១៧២ អនក្រ.តត ស្តីពី ការជូនមេដាយស្ថាបនាជាតិ ២២០៧
១៩-០២-២០១៦ -អនុក្រឹត្យលេខ ១៧៣ អនក្រ.តត ស្តីពី ការជូនមេដាយមុនីសារាភ័ណ្ឌ ២២០៨
១៩-០២-២០១៦ -អនុក្រឹត្យលេខ ១៧៤ អនក្រ.តត ស្តីពី ការជូនមេដាយស្ថាបនាជាតិ ២២០៩
១៩-០២-២០១៦ -អនុក្រឹត្យលេខ ១៧៥ អនក្រ.តត ស្តីពី ការជូនមេដាយមុនីសារាភ័ណ្ឌ ២២១០
១៩-០២-២០១៦ -អនុក្រឹត្យលេខ ១៧៦ អនក្រ.តត ស្តីពី ការជូនមេដាយស្ថាបនាជាតិ ២២១២
១៩-០២-២០១៦ -អនុក្រឹត្យលេខ ១៧៧ អនក្រ.តត ស្តីពី ការជូនមេដាយការងារ ២២១៤
១៩-០២-២០១៦ -អនុក្រឹត្យលេខ ១៧៨ អនក្រ.តត ស្តីពី ការជូនមេដាយមុនីសារាភ័ណ្ឌ ២២១៦

## ២_សេចក្តីសម្រេច

០៣-០៣-២០១៦ -សេចក្តីសម្រេចលេខ ១៩ សសរ ស្តីពី ការបង្កើតគណៈកម្មការអន្តរក្រសួង ដើម្បីសិក្សាពីលទ្ធភាពបង្កើតឧទ្យានជាតិសមុទ្រកោះរុង ដែលមានទីតាំងនៅតំបន់កោះរុង ២២១៧

០៣-០៣-២០១៦ -សេចក្តីសម្រេចលេខ ២១ សសរ ស្តីពី ការបង្កើតគណៈកម្មការអន្តរក្រសួងសម្រាប់ពិនិត្យ និងរៀបចំគោលនយោបាយជាតិ ស្តីពី ការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ ២២២០

## III-ការងារបណ្តាក្រសួង

### ១-ទីស្តីការរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

០៩-០២-២០១៦ -ប្រកាសអន្តរក្រសួងលេខ ១១៣ សហវ.ប្រក ស្តីពី ការបង្កើតរង្វាន់ទេយ្យបុរេប្រទាន សម្រាប់ឆ្នាំ ២០១៦ របស់ក្រសួងមុខងារសាធារណៈ ២២២៣

១០-០២-២០១៦ -ប្រកាសលេខ ១១៩ សហវ.ប្រក ស្តីពី ការបង្កើតគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងកម្មវិធីកំណែទម្រង់ និងទំនើបកម្មគយ ២២២៧

១០-០២-២០១៦ -សេចក្តីសម្រេចលេខ ០០៣ សហវ ស្តីពី ការតែងតាំងសមាសភាពគណៈកម្មាធិការវាយតំលៃសមិទ្ធកម្ម និងការផ្តល់ការលើកទឹកចិត្តរបស់អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា ២២៣០

### ២-ទីស្តីការរដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និង សិប្បកម្ម

២០-១១-២០១៥ -ប្រកាសលេខ ៦៨៦ ឧស.កឧ.ប្រក.១១ ស្តីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន យីវ ហ្វៃកែកឃីង (ខេមបូឌា) លីមីធីត បង្កើតរោងចក្រ ផលិតថង់ប្លាស្ទិកគ្រប់ប្រភេទ ២២៣២

២០-១១-២០១៥ -ប្រកាសលេខ ៦៨៧ ឧស.កឧ.ប្រក.១១ ស្តីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន ស៊ុដស៍ ហ្គាមេន (ខេមបូឌា) បង្កើតរោងចក្រ កាត់ដេរ និងប៉ាក់សម្លៀកបំពាក់ ២២៣៥

២០-១១-២០១៥ -ប្រកាសលេខ ៦៨៨ ឧស.កឧ.ប្រក.១១ ស្តីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន វីកូតិច អ៊ិនដាសស្ទ្រៀល បង្កើតរោងចក្រ កាត់ដេរសម្លៀកបំពាក់ ២២៣៨

# ព្រះរាជក្រឹត្យ

នស/រកត/០២១៦/២០៥

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស / រកត / ០៩១៣ / ៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស / រកម / ១០៩៦ / ៣០ ចុះថ្ងៃទី០៩ ខែតុលា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីសញ្ជាតិ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១** : ផ្តល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្មដល់កញ្ញា **វឌ្ឍនាបុក្កា អនឈុម៉ា** (VATJANAPUKKA ORNCHUMA) ជនជាតិថៃ សញ្ជាតិថៃ កើតថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ១៩៩៧ នៅរាជធានីបាងកក ព្រះរាជាណាចក្រថៃឡង់ដ៏។

**មាត្រា ២** : សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

៣៧. ១៦០៥. ២០៧

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ១៥ ខែ កុម្ភៈ ឆ្នាំ ២០១៦

លេខៈ ១៨៥ ស.ណ
**សំណៅដែលមានតម្លៃជាការចែកផ្សាយ**
រាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែ កុម្ភៈ ឆ្នាំ២០១៦
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សយ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/០២១៦/២០៣

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/១០៩៦/៣០ ចុះថ្ងៃទី០៩ ខែតុលា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីសញ្ជាតិ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១ :** ផ្តល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្មដល់លោក **ស៊ូ ជីឈីង** (SU ZIQING) ជនជាតិចិន សញ្ជាតិចិន កើតថ្ងៃទី១៧ ខែមីនា ឆ្នាំ១៩៧៨ នៅខេត្តហ្វូជៀន សាធារណរដ្ឋប្រជាមានិតចិន។

**មាត្រា ២ :** សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

*ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ១៥ ខែ កុម្ភៈ ឆ្នាំ ២០១៦*

លេខៈ ១៨៩ ស.ណ
**សំណៅចំលងមានតម្លៃជាការចែកផ្សាយ**
រាជធានីភ្នំពេញ ,ថ្ងៃទី ១៦ ខែ កុម្ភៈ ឆ្នាំ២០១៦
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សយ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/០២១៦/២០៤

យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/១០៩៦/៣០ ចុះថ្ងៃទី០៩ ខែតុលា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីសញ្ជាតិ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

**ត្រាស់បង្គាប់**

**មាត្រា ១ :** ផ្តល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្មដល់លោក **ចាង គួតុង** (ZHANG GUODONG) ជនជាតិចិន សញ្ជាតិចិន កើតថ្ងៃទី១៩ ខែមករា ឆ្នាំ១៩៧៧ នៅខេត្តសានទុង សាធារណរដ្ឋប្រជាមានិតចិន ដោយប្តូរឈ្មោះជា **ចាង លាង** (ZHANG LEANG)។

**មាត្រា ២ :** សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

ពរស. ១៦០៤. ២០៩

*ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ១៤ ខែ កុម្ភៈ ឆ្នាំ ២០១៦*

លេខៈ ១៩១ ស.ណ
**សំណៅចែលមានតម្លៃជាការចែកផ្សាយ**
រាជធានីភ្នំពេញ .ថ្ងៃទី ១៥ ខែ កុម្ភៈ ឆ្នាំ២០១៦
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

សយ សុខា

# ព្រះរាជក្រឹត្យ

នស/រកត/០២១៦/៤០៥

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស / រកត / ០៩១៣ / ៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស / រកម / ១០៩៦ / ៣០ ចុះថ្ងៃទី០៩ ខែតុលា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីសញ្ជាតិ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១** : ផ្តល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្មដល់លោក **ចូវ ជិនឈិន** (ZHOU JINCHENG) ជនជាតិចិន សញ្ជាតិចិន កើតថ្ងៃទី១៥ ខែសីហា ឆ្នាំ១៩៦៨ នៅខេត្តក្វាងទុង សាធារណរដ្ឋប្រជាមានិតចិន។

**មាត្រា ២** : សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

៣៧. ១៦០៥. ៤១០

*ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ១៤ ខែ កុម្ភៈ ឆ្នាំ ២០១៦*

លេខៈ ១១៨ ស.ណ
**សំណៅចម្លងដែលមានតម្លៃជាការចែកផ្សាយ**
រាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែ កុម្ភៈ ឆ្នាំ២០១៦
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

សយ សុខា

# ព្រះរាជក្រឹត្យ

នស/រកត/០២១៦/២០៧

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៥ ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១២១៤/១៤៩៣ ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០១៤ ស្តីពីការគ្រប់គ្រងនិងការបើកផ្តល់ប្រាក់បំណាច់ជូនទីប្រឹក្សា ជំនួយការ លេខាធិការ និងមន្ត្រីដែលមានឋានៈស្មើ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា១**.- តែងតាំងមុខតំណែង និងផ្តល់ឋានៈលោកជំទាវ **សែម លីណា** ជាទីប្រឹក្សាក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច មានឋានៈស្មើអគ្គនាយក ។

**មាត្រា២**.- សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

៣៧៧. ១៦០៥. ២១៥

លេខ: ២១៩ ស.ណ
សំណៅចម្លងដែលមានតម្លៃជាការចែកផ្សាយ
រាជធានីភ្នំពេញ ថ្ងៃទី ២៣ ខែ កុម្ភៈ ឆ្នាំ២០១៦
អគ្គលេខាធិការរាជរដ្ឋាភិបាល

*ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ១៨ ខែ កុម្ភៈ ឆ្នាំ ២០១៦*

**ស៊យ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/០២១៦/៤០៧

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

-បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែកញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ

-បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១**: តែងតាំង និងផ្តល់ឋានៈជាទីប្រឹក្សា**សម្តេចក្រឡាហោម ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ចំនួន ០២ រូបៈ

១-ឯកឧត្តម **អ៊ិន រស្មីរិទ្ធី** ទីប្រឹក្សាមានឋានៈស្មើ រដ្ឋលេខាធិការ ដោយមិនយកប្រាក់បៀវត្ស

២-ឯកឧត្តម **សា ផល្លី** ទីប្រឹក្សាមានឋានៈស្មើ រដ្ឋលេខាធិការ ដោយមិនយកប្រាក់បៀវត្ស។

**មាត្រា ២** :សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**

**នរោត្តម សីហមុនី**

លេខៈ២៧៧១ ស.ណ

**សំណៅដែលមានតម្លៃជាការចែកផ្សាយ**

រាជធានីភ្នំពេញ ,ថ្ងៃទី ២៤ ខែកុម្ភៈ ឆ្នាំ២០១៦

**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សយ សុខា**

៣៧. ១៦០២. ៤១៣

*ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ១៨ ខែ កុម្ភៈ ឆ្នាំ ២០១៦*

នស/រកត/០២១៦/៤០៩

# ព្រះរាជក្រឹត្យ

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សម្ពោហនាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ ជស/រកត/០២០០/១០៤ ចុះថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០០០ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីរដ្ឋបាលជាន់ខ្ពស់ ក្រសួងមហាផ្ទៃ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៥០១/១៧៨ ចុះថ្ងៃទី២២ ខែឧសភា ឆ្នាំ២០០១ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា១ :** ផ្ទេរក្របខ័ណ្ឌលោក **ឃី តារាលី** ពីឋានន្តរសក្តិអនុមន្ត្រីថ្នាក់លេខ៣ នៃក្របខ័ណ្ឌមន្ត្រីរដ្ឋបាលជាន់ខ្ពស់ ក្រសួងមហាផ្ទៃ មកក្នុងក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា ក្រសួងមហាផ្ទៃ ។

**មាត្រា២ :** តែងតាំងឋានន្តរសក្តិ **ឧត្តមសេនីយ៍ត្រី** ដល់លោក **ឃី តារាលី** អត្តលេខ ៧៨០០២ នាយនគរបាលថ្នាក់ឧត្តមសេនីយ៍ ក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា នៃក្រសួងមហាផ្ទៃ ។

**មាត្រា៣ :** បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា៤ :** សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**

**នរោត្តម សីហមុនី**

៣៧.១៦០៤.៤១៤

*ធ្វើនៅព្រះបរមរាជវាំង,ថ្ងៃទី ១៥ ខែ កុម្ភៈ ឆ្នាំ ២០១៦*

លេខ: ៤២៣ ស.ណ

**សំណៅដែលមានសេចក្តីដូចការចែកផ្សាយ**

រាជធានីភ្នំពេញ ថ្ងៃទី ២៥ ខែ កុម្ភៈ ឆ្នាំ២០១៦

**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សយ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/០២១៦/៤១០

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានត្ថមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៧ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើត ក្រសួងការពារជាតិ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧០១/២៣៧ ចុះថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ ២០០១ ស្តីពីការកែសម្រួលតួនាទីភារកិច្ចនិងរចនាសម្ព័ន្ធចាត់តាំងរបស់ អគ្គបញ្ជាការដ្ឋាននៃកងយោធពលខេមរភូមិន្ទ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់ សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា១ :** តម្លើងឋានន្តរស័ក្តិ ដល់ នាយទាហាន ថ្នាក់ឧត្តមសេនីយ៍ និងថ្នាក់វរសេនីយ៍ នៃកងយោធពលខេមរភូមិន្ទ ៖

**ក-ឋានន្តរស័ក្តិឧត្តមសេនីយ៍ឯក**

១-ឧត្តមសេនីយ៍ទោ **ប៊ុន ដារ៉ា** អត្តលេខ ០០៥២៧៦
២-ឧត្តមសេនីយ៍ទោ **ពៅ កក្កដា** អត្តលេខ ០១៧៧២០
៣-ឧត្តមសេនីយ៍ទោ **ហ៊ិន ផាន់** អត្តលេខ ០១១៧៨៥
៤-ឧត្តមសេនីយ៍ទោ **អ៊ុន សារិន** អត្តលេខ ០០៣៨៥២
៥-ឧត្តមសេនីយ៍ទោ **អឿន ចយ** អត្តលេខ ០០៨៦៣១
៦-ឧត្តមសេនីយ៍ទោ **ឈាង ចាន់មុន្នី** អត្តលេខ ០១៥២២៣
៧-ឧត្តមសេនីយ៍ទោ **សំ សាមឿន** អត្តលេខ ០០៤០០៥
៨-ឧត្តមសេនីយ៍ទោ **ផាត់ តា** អត្តលេខ ០១៧៧១៣
៩-ឧត្តមសេនីយ៍ទោ **ម៉ែន សុខ** អត្តលេខ ០០៤០៩៥
១០-ឧត្តមសេនីយ៍ទោ **ឌី ពៅ** អត្តលេខ ០០៩៦៧៧
១១-ឧត្តមសេនីយ៍ទោ **ស្រួល សុខជា** អត្តលេខ ០១១៧៧៨
១២-ឧត្តមសេនីយ៍ទោ **ព្រាប លីណា** អត្តលេខ ០០១០៩៩
១៣-ឧត្តមសេនីយ៍ទោ **ប៊ុន ថន** អត្តលេខ ០១១៧០៤

**ខ-ឋានន្តរស័ក្តិឧត្តមសេនីយ៍ទោ**

១-ឧត្តមសេនីយ៍ត្រី **អ៊ុក អ៊ុន** អត្តលេខ ០០៣៣២៩
២-ឧត្តមសេនីយ៍ត្រី **តេង សុខា** អត្តលេខ ០០៣៧៧២
៣-ឧត្តមសេនីយ៍ត្រី **ប៊ុន ឆាយ** អត្តលេខ ០០៥១៧៣

| | | | |
|---|---|---|---|
| ៤-ឧត្តមសេនីយ៍ត្រី | កេត | សំអាត | អត្តលេខ ០០២៨៣៦ |
| ៥-ឧត្តមសេនីយ៍ត្រី | ហេង | សំណាង | អត្តលេខ ០៣២៥៥២ |
| ៦-ឧត្តមសេនីយ៍ត្រី | ចាន់ | ណារិទ្ធ | អត្តលេខ ០០៤០៧៣ |
| ៧-ឧត្តមសេនីយ៍ត្រី | ឡូន | មករា | អត្តលេខ ០៣២៦១៩ |
| ៨-ឧត្តមសេនីយ៍ត្រី | ណុប | ម៉ុនថាវ | អត្តលេខ ០២៦៤៨៣ |
| ៩-ឧត្តមសេនីយ៍ត្រី | ហ៊ី | ប៉េង | អត្តលេខ ០២១០៨០ |
| ១០-ឧត្តមសេនីយ៍ត្រី | សាយ | នី | អត្តលេខ ០១៥៨៥២ |
| ១១-ឧត្តមសេនីយ៍ត្រី | នួវ | សារិទ្ធ | អត្តលេខ ០១១៧៧៩ |
| ១២-ឧត្តមសេនីយ៍ត្រី | ឈិញ | សុវណ្ណា | អត្តលេខ ០២១១៣៩ |
| ១៣-ឧត្តមសេនីយ៍ត្រី | ម៉ម | ស៊ីថា | អត្តលេខ ០០៣៣៣៦ |
| ១៤-ឧត្តមសេនីយ៍ត្រី | ហុង | ណារិទ្ធ | អត្តលេខ ១០៦៩៦២ |
| ១៥-ឧត្តមសេនីយ៍ត្រី | ទ៉ាន់ | វិសាល | អត្តលេខ ០២១១៤៥ |
| ១៦-ឧត្តមសេនីយ៍ត្រី | លី | ភក្តី | អត្តលេខ ០២១០៧៦ |
| ១៧-ឧត្តមសេនីយ៍ត្រី | យុង | សំអុល | អត្តលេខ ០២១០៥៩ |
| ១៨-ឧត្តមសេនីយ៍ត្រី | ណុប | រតនៈ | អត្តលេខ ០៨៨៦០១ |

**គ-ឋានន្តរស័ក្តិឧត្តមសេនីយ៍ត្រី**

| | | | |
|---|---|---|---|
| ១-វរសេនីយ៍ឯក | លី | ឧត្តម | អត្តលេខ ២១៩២៥៦ |
| ២-វរសេនីយ៍ឯក | ចាន់ | ដេវីត | អត្តលេខ ១៧៩៤០៥ |
| ៣-វរសេនីយ៍ឯក | តាជ | គឹមសុង | អត្តលេខ ០០៤០៧០ |
| ៤-វរសេនីយ៍ឯក | អេា | ខ្លា | អត្តលេខ ០២១០២១ |
| ៥-វរសេនីយ៍ឯក | អៀង | ចន្ថា | អត្តលេខ ០៨០០១៦ |
| ៦-វរសេនីយ៍ឯក | នៅ | ម៉ុនធឿន | អត្តលេខ ១០៣៨៩៤ |
| ៧-វរសេនីយ៍ឯក | ខឹម | ឬទ្ធី | អត្តលេខ ០២១១៦៤ |
| ៨-វរសេនីយ៍ឯក | លន់ | សាវី | អត្តលេខ ២៣២០៩៨ |
| ៩-វរសេនីយ៍ឯក | ណុប គឹមសាន្ត | | អត្តលេខ ១៦២១៤៨ |
| ១០-វរសេនីយ៍ឯក | នួវ | ចន្ថន | អត្តលេខ ១៥១៣៣៥ |
| ១១-វរសេនីយ៍ឯក | លី | យូគៀក | អត្តលេខ ០៣៨៩៤១ |
| ១២-វរសេនីយ៍ឯក | ស៊ូ | សុផាន | អត្តលេខ ០២១២៥៥ |
| ១៣-វរសេនីយ៍ឯក | អ៊ី | សារី | អត្តលេខ ០២១០៦៦ |
| ១៤-វរសេនីយ៍ឯក | គង់ | ម៉ុននី | អត្តលេខ ១៦២២២៥ |
| ១៥-វរសេនីយ៍ឯក | ឡុង | សត្យា | អត្តលេខ ០៥០៦៤៥ |
| ១៦-វរសេនីយ៍ឯក | ឡេង | សាម៉េត | អត្តលេខ ១៣៧៦៨២ |
| ១៧-វរសេនីយ៍ឯក | ឆែម រតនៈវិសាល | | អត្តលេខ ២០៨៩០៥ |
| ១៨-វរសេនីយ៍ឯក | ហុង | យ៉េន | អត្តលេខ ១៣៨០១០ |

**មាត្រា២៖** សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្ត ព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ

នរោត្តម សីហមុនី

៣៩៧.១៦០៤.២១៥

*ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ១៧ ខែ កុម្ភៈ ឆ្នាំ ២០១៦*

លេខៈ [illegible] ស.ណ

សំណៅដែលមានតម្លៃជាការចែកផ្សាយ

រាជធានីភ្នំពេញ ,ថ្ងៃទី ២៥ ខែ កុម្ភៈ ឆ្នាំ២០១៦

អគ្គលេខាធិការរាជរដ្ឋាភិបាល

សយ សុខា

# ព្រះរាជក្រឹត្យ

នស/រកត/០២១៦/៤១១

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១០៥/០០៣ ចុះថ្ងៃទី ១៧ ខែ មករា ឆ្នាំ ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៦០២/១៥១ ចុះថ្ងៃទី ០៩ ខែ មិថុនា ឆ្នាំ ២០០២ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីបច្ចេកទេសជាន់ខ្ពស់
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១០១៤/១១៧៥ ចុះថ្ងៃទី ០២ ខែ តុលា ឆ្នាំ ២០១៤ ស្តីពីគោលការណ៍រួមនៃការរៀបចំមុខងារសាធារណៈរបស់រដ្ឋ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១ :** តាំងស៊ប់ក្នុងក្របខ័ណ្ឌ ដល់ មន្ត្រីរាជការ **៥២** រូប ទៅក្នុងឋានន្តរស័ក្តិមន្ត្រីបច្ចេកទេសជាន់ខ្ពស់ នៃក្របខ័ណ្ឌមន្ត្រីបច្ចេកទេសជាន់ខ្ពស់ របស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ចាប់ពីថ្ងៃទី ០១ ខែ តុលា ឆ្នាំ **២០១៥** ៖

| | |
|---|---|
| ១- លោកស្រី **ឡេង លីណា** | មន្ត្រីបច្ចេកទេសជាន់ខ្ពស់ ថ្នាក់លេខ ៤ |
| ២- លោកស្រី **ងី សោភ័ណា** | មន្ត្រីបច្ចេកទេសជាន់ខ្ពស់ ថ្នាក់លេខ ៤ |

| | |
|---|---|
| ៣- លោកស្រី **ត្រី ស្រីនាថ** | មន្ត្រីបច្ចេកទេសជាន់ខ្ពស់ ថ្នាក់លេខ ៤ |
| ៤- លោកស្រី **ស៊ីង ច័ន្ទរក្សា** | មន្ត្រីបច្ចេកទេសជាន់ខ្ពស់ ថ្នាក់លេខ ៤ |
| ៥- លោកស្រី **ឡាយ ម៉ារីណា** | មន្ត្រីបច្ចេកទេសជាន់ខ្ពស់ ថ្នាក់លេខ ៤ |
| ៦- លោក **ឧត ឆេងឡៀង** | មន្ត្រីបច្ចេកទេសជាន់ខ្ពស់ ថ្នាក់លេខ ៤ |
| ៧- លោកស្រី **ស៊ឹម ចិន្តា** | មន្ត្រីបច្ចេកទេសជាន់ខ្ពស់ ថ្នាក់លេខ ៤ |
| ៨- លោកស្រី **រឿន សុវ៉ានី** | មន្ត្រីបច្ចេកទេសជាន់ខ្ពស់ ថ្នាក់លេខ ៤ |
| ៩- លោក **ថន សុធីរ៉ាត់** | មន្ត្រីបច្ចេកទេសជាន់ខ្ពស់ ថ្នាក់លេខ ៤ |
| ១០- លោក **តាំង ម៉េងលី** | មន្ត្រីបច្ចេកទេសជាន់ខ្ពស់ ថ្នាក់លេខ ៤ |
| ១១- លោកស្រី **ហែម សុខរីដា** | មន្ត្រីបច្ចេកទេសជាន់ខ្ពស់ ថ្នាក់លេខ ៤ |
| ១២- លោកស្រី **ហួត ផល្លា** | មន្ត្រីបច្ចេកទេសជាន់ខ្ពស់ ថ្នាក់លេខ ៤ |
| ១៣- លោក **ហេង ហ៊័រ** | មន្ត្រីបច្ចេកទេសជាន់ខ្ពស់ ថ្នាក់លេខ ៤ |
| ១៤- លោកស្រី **គង់ សុវាចា** | មន្ត្រីបច្ចេកទេសជាន់ខ្ពស់ ថ្នាក់លេខ ៤ |
| ១៥- លោកស្រី **ហឿន សិលា** | មន្ត្រីបច្ចេកទេសជាន់ខ្ពស់ ថ្នាក់លេខ ៤ |
| ១៦- លោក **ទិត ចាន់ថន** | មន្ត្រីបច្ចេកទេសជាន់ខ្ពស់ ថ្នាក់លេខ ៤ |
| ១៧- លោក **ណុប ពិសី** | មន្ត្រីបច្ចេកទេសជាន់ខ្ពស់ ថ្នាក់លេខ ៤ |
| ១៨- លោកស្រី **ខៀវ ស្រីនាង** | មន្ត្រីបច្ចេកទេសជាន់ខ្ពស់ ថ្នាក់លេខ ៤ |
| ១៩- លោកស្រី **ផង់ ច័ន្ទដាវី** | មន្ត្រីបច្ចេកទេសជាន់ខ្ពស់ ថ្នាក់លេខ ៤ |
| ២០- លោក **អ៊ឹងលាក់ សិទ្ធហោះ** | មន្ត្រីបច្ចេកទេសជាន់ខ្ពស់ ថ្នាក់លេខ ៤ |
| ២១- លោកស្រី **ម៉ុក បុប្ផា** | មន្ត្រីបច្ចេកទេសជាន់ខ្ពស់ ថ្នាក់លេខ ៤ |
| ២២- លោក **ពិន តារី** | មន្ត្រីបច្ចេកទេសជាន់ខ្ពស់ ថ្នាក់លេខ ៤ |
| ២៣- លោក **យ៉ាន កុម្ភៈ** | មន្ត្រីបច្ចេកទេសជាន់ខ្ពស់ ថ្នាក់លេខ ៤ |
| ២៤- លោកស្រី **ពុទ្ធ បញ្ញា** | មន្ត្រីបច្ចេកទេសជាន់ខ្ពស់ ថ្នាក់លេខ ៤ |
| ២៥- លោកស្រី **ជិន វិបុល** | មន្ត្រីបច្ចេកទេសជាន់ខ្ពស់ ថ្នាក់លេខ ៤ |
| ២៦- លោក **មួង មួយអ៊ាង** | មន្ត្រីបច្ចេកទេសជាន់ខ្ពស់ ថ្នាក់លេខ ៤ |
| ២៧- លោកស្រី **ថៃ សិរីអូរ៉ានី** | មន្ត្រីបច្ចេកទេសជាន់ខ្ពស់ ថ្នាក់លេខ ៤ |
| ២៨- លោក **យិន ពេជ្ររចនា** | មន្ត្រីបច្ចេកទេសជាន់ខ្ពស់ ថ្នាក់លេខ ៤ |
| ២៩- លោក **លាង ឈាងឡេង** | មន្ត្រីបច្ចេកទេសជាន់ខ្ពស់ ថ្នាក់លេខ ៤ |
| ៣០- លោកស្រី **ហេង សារ៉ាលីន** | មន្ត្រីបច្ចេកទេសជាន់ខ្ពស់ ថ្នាក់លេខ ៤ |
| ៣១- លោក **លៀម មុន្នី** | មន្ត្រីបច្ចេកទេសជាន់ខ្ពស់ ថ្នាក់លេខ ៤ |
| ៣២- លោកស្រី **ឯម សុខសាន្ត** | មន្ត្រីបច្ចេកទេសជាន់ខ្ពស់ ថ្នាក់លេខ ៤ |



| | |
|---|---|
| ៣៣- លោកស្រី **អ៊ុន គឹមហ៊ា** | មន្ត្រីបច្ចេកទេសជាន់ខ្ពស់ ថ្នាក់លេខ ៤ |
| ៣៤- លោក **ហ្វូ ធីណារ៉ា** | មន្ត្រីបច្ចេកទេសជាន់ខ្ពស់ ថ្នាក់លេខ ៤ |
| ៣៥- លោកស្រី **សយ មករា** | មន្ត្រីបច្ចេកទេសជាន់ខ្ពស់ ថ្នាក់លេខ ៤ |
| ៣៦- លោក **អ៊ុច ស៊ីថុល** | មន្ត្រីបច្ចេកទេសជាន់ខ្ពស់ ថ្នាក់លេខ ៤ |
| ៣៧- លោកស្រី **អ៊ុំ ស្រីពៅ** | មន្ត្រីបច្ចេកទេសជាន់ខ្ពស់ ថ្នាក់លេខ ៤ |
| ៣៨- លោកស្រី **កែវ ចាន់ណា** | មន្ត្រីបច្ចេកទេសជាន់ខ្ពស់ ថ្នាក់លេខ ៤ |
| ៣៩- លោកស្រី **ឈ ផារី** | មន្ត្រីបច្ចេកទេសជាន់ខ្ពស់ ថ្នាក់លេខ ៤ |
| ៤០- លោក **អ៊ុង រតនឧត្តម** | មន្ត្រីបច្ចេកទេសជាន់ខ្ពស់ ថ្នាក់លេខ ៤ |
| ៤១- លោក **តា ហៀ** | មន្ត្រីបច្ចេកទេសជាន់ខ្ពស់ ថ្នាក់លេខ ៤ |
| ៤២- លោក **គត់ ចាន់រ៉ែត** | មន្ត្រីបច្ចេកទេសជាន់ខ្ពស់ ថ្នាក់លេខ ៤ |
| ៤៣- លោកស្រី **ផាវ ស៊ីនាត** | មន្ត្រីបច្ចេកទេសជាន់ខ្ពស់ ថ្នាក់លេខ ៤ |
| ៤៤- លោកស្រី **រឿន ច័ន្ទសុជានីត** | មន្ត្រីបច្ចេកទេសជាន់ខ្ពស់ ថ្នាក់លេខ ៤ |
| ៤៥- លោកស្រី **ឡុង មុនីរ័ត្ន** | មន្ត្រីបច្ចេកទេសជាន់ខ្ពស់ ថ្នាក់លេខ ៤ |
| ៤៦- លោកស្រី **លឹម សុខជា** | មន្ត្រីបច្ចេកទេសជាន់ខ្ពស់ ថ្នាក់លេខ ៤ |
| ៤៧- លោកស្រី **យឿម សំណាង** | មន្ត្រីបច្ចេកទេសជាន់ខ្ពស់ ថ្នាក់លេខ ៤ |
| ៤៨- លោក **ឈន សំបូរ** | មន្ត្រីបច្ចេកទេសជាន់ខ្ពស់ ថ្នាក់លេខ ៤ |
| ៤៩- លោកស្រី **នាង សុភ័ក្រ** | មន្ត្រីបច្ចេកទេសជាន់ខ្ពស់ ថ្នាក់លេខ ៤ |
| ៥០- លោក **ហាន សាវ៉ាត** | មន្ត្រីបច្ចេកទេសជាន់ខ្ពស់ ថ្នាក់លេខ ៤ |
| ៥១- លោកស្រី **ហុង ម៉ានី** | មន្ត្រីបច្ចេកទេសជាន់ខ្ពស់ ថ្នាក់លេខ ៤ |
| ៥២- លោក **ផន់ វិបុល** | មន្ត្រីបច្ចេកទេសជាន់ខ្ពស់ ថ្នាក់លេខ ៤ |

**មាត្រា ២ :** សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**

**នរោត្តម សីហមុនី**

ពរ៧.១៦០៤-៤១៦

*ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ១៤ ខែ កុម្ភៈ ឆ្នាំ ២០១៦*

លេខ: ៧២៤ ស.ណ

**សំណៅចម្លងដែលមានតម្លៃជាការចែកផ្សាយ**

រាជធានីភ្នំពេញ ,ថ្ងៃទី ២៤ ខែ កុម្ភៈ ឆ្នាំ២០១៦

**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សយ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/០២១៦/២១៤

យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស / រកត / ០៩១៣ / ៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស / រកម / ១០៩៦ / ៣០ ចុះថ្ងៃទី០៩ ខែតុលា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីសញ្ជាតិ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១ :** ផ្តល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្មដល់លោក **លី វៃ ហ្វុង** (LI WAI FUNG) ជនជាតិចិន សញ្ជាតិចិន កើតថ្ងៃទី១៥ ខែសីហា ឆ្នាំ១៩៦៤ នៅខេត្តក្វាងទុង សាធារណរដ្ឋប្រជាមានិតចិន។

**មាត្រា ២ :** សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

ពរស-១៦០២.២១៧

*ធ្វើនៅព្រះបរមរាជវាំង,ថ្ងៃទី ១៤ ខែ កុម្ភៈ ឆ្នាំ ២០១៦*

លេខ: ២១៦ ស.ណ
**សំណៅចែលមានតម្លៃជាការចែកផ្សាយ**
រាជធានីភ្នំពេញ ថ្ងៃទី ២៣ ខែ កុម្ភៈ ឆ្នាំ២០១៦
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សយ សុខា**

នស/រកត/០២១៦/២១៧

# ព្រះរាជក្រឹត្យ

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/១០៩៦/៣០ ចុះថ្ងៃទី០៩ ខែតុលា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីសញ្ជាតិ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១ :** ផ្តល់សញ្ជាតិខ្មែរ ដោយអាពាហ៍ពិពាហ៍ដល់អ្នកស្រី **សិរិណាត ផល្លាបុត្រ** (SIRINARD PONLA-BUTE) ជនជាតិថៃ សញ្ជាតិថៃ កើតថ្ងៃទី០៥ ខែមិថុនា ឆ្នាំ១៩៥៨ នៅខេត្តពេជ្របុរី ព្រះរាជាណាចក្រថៃឡង់ដ៍ ដោយប្តូរឈ្មោះជា **លីម សិរិណាត** (LIM SIRINARD)។

**មាត្រា ២ :** សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

៣៩៧.១៦០២.២១៧

ធ្វើនៅព្រះបរមរាជវាំង,ថ្ងៃទី ១២ ខែ កុម្ភៈ ឆ្នាំ ២០១៦

លេខ: ២១៧ស.ណ
**សំណៅដែលមានតម្លៃជាការចែកផ្សាយ**
រាជធានីភ្នំពេញ ,ថ្ងៃទី ២៣ ខែ កុម្ភៈ ឆ្នាំ២០១៦
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សយ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/០២១៦/៥១៨

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សម្ហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស / រកត / ០៩១៣ / ៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស / រកម / ១០៩៦ / ៣០ ចុះថ្ងៃទី០៩ ខែតុលា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីសញ្ជាតិ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១** : ផ្តល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្មដល់អ្នកស្រី **អ៊ូ ជូលីង** (WU JUI-LING) ជនជាតិចិនតៃវ៉ាន់ សញ្ជាតិចិនតៃវ៉ាន់ កើតថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ១៩៧៥ នៅខេត្តតៃវ៉ាន់ សាធារណរដ្ឋចិន។

**មាត្រា ២** : សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

ព.រក. ១៦០៤.៥១៩

*ធ្វើនៅព្រះបរមរាជវាំង,ថ្ងៃទី ១៨ ខែ កុម្ភៈ ឆ្នាំ ២០១៦*

លេខ: ២១៨ ស.ណ
**សំណៅដែលមានតម្លៃជាការចែកផ្សាយ**
រាជធានីភ្នំពេញ ,ថ្ងៃទី ២៣ ខែ កុម្ភៈ ឆ្នាំ២០១៦
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សយ សុខា**

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រុមប្រឹក្សាធម្មនុញ្ញ**

**សំណុំរឿង**

លេខ : ២៦០/០០១/២០១៦

ចុះថ្ងៃទី ១០ ខែ កុម្ភៈ ឆ្នាំ២០១៦

**សេចក្តីសម្រេច**

លេខ : ១៥៩/០០១/២០១៦ កបធ.ច

ចុះថ្ងៃទី ០៣ ខែ មីនា ឆ្នាំ២០១៦

## ក្រុមប្រឹក្សាធម្មនុញ្ញ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០៤៩៨/០៦ ចុះថ្ងៃទី ០៨ ខែ មេសា ឆ្នាំ១៩៩៨ ប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៧/០០៥ ចុះថ្ងៃទី ៣១ ខែ មករា ឆ្នាំ២០០៧ ប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានឃើញសំណើលេខ ០៦៣ រ.ស ចុះថ្ងៃទី ១០ ខែ កុម្ភៈ ឆ្នាំ២០១៦ របស់សម្តេចអគ្គមហាពញាចក្រី **ហេង សំរិន** ប្រធានរដ្ឋសភា ស្នើសុំក្រុមប្រឹក្សាធម្មនុញ្ញពិនិត្យធម្មនុញ្ញភាពនៃច្បាប់ស្តីពីគណនេយ្យ និងសវនកម្ម ដែលរដ្ឋសភាបានអនុម័តនៅថ្ងៃទី ១៤ ខែ មករា ឆ្នាំ២០១៦ នាសម័យប្រជុំលើកទី៥ នីតិកាលទី៥ និងព្រឹទ្ធសភាបានពិនិត្យ និងឱ្យយោបល់ឯកភាពទាំងស្រុងលើទម្រង់ និង គតិច្បាប់ដោយឥតកែប្រែក្នុងសម័យប្រជុំលើកទី៨ នីតិកាលទី៣ នាថ្ងៃទី ០៥ ខែ កុម្ភៈ ឆ្នាំ២០១៦ ហើយដែលអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញបានទទួលនៅថ្ងៃទី ១០ ខែ កុម្ភៈ ឆ្នាំ២០១៦ វេលាម៉ោង ១៦ និង ៣០ នាទី

**ក្រោយពីបានស្តាប់របាយការណ៍របស់សមាជិករាយការណ៍**

**ក្រោយពីបានស្តាប់ការបំភ្លឺរបស់តំណាងរាជរដ្ឋាភិបាល**

**ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ**

- យល់ឃើញថា រដ្ឋសភា និង ព្រឹទ្ធសភាបានអនុវត្តយ៉ាងត្រឹមត្រូវតាមបែបបទដែលមានចែងក្នុងមាត្រា ១១៣ ថ្មី នៃរដ្ឋធម្មនុញ្ញ ក្នុងការពិនិត្យ និង អនុម័តច្បាប់ស្តីពីគណនេយ្យ និងសវនកម្ម
- យល់ឃើញថា សំណើរបស់សម្តេចអគ្គមហាពញាចក្រី **ហេង សំរិន** ប្រធានរដ្ឋសភា ស្របនឹងមាត្រា ១៤០ ថ្មី នៃរដ្ឋធម្មនុញ្ញ និងមាត្រា ១៦ថ្មី នៃច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ ។ ដូច្នេះ ក្រុមប្រឹក្សាធម្មនុញ្ញអាចទទួលយកសំណើសុំពិនិត្យធម្មនុញ្ញភាពនៃច្បាប់នេះ មកពិនិត្យបាន
- យល់ឃើញថា ទម្រង់នៃការតាក់តែង និងការអនុម័តច្បាប់ស្តីពីគណនេយ្យ និងសវនកម្ម ស្របនឹងរដ្ឋធម្មនុញ្ញ
- យល់ឃើញថា តាមការឆ្លើយបំភ្លឺរបស់តំណាងរាជរដ្ឋាភិបាលលើចំណុចមួយចំនួននៃច្បាប់ស្តីពីគណនេយ្យ និងសវនកម្ម ក្នុងកិច្ចប្រជុំក្រុមប្រឹក្សាធម្មនុញ្ញកាលពីថ្ងៃទី ២៦ ខែ កុម្ភៈ ឆ្នាំ២០១៦ តាមការអញ្ជើញរបស់ក្រុមប្រឹក្សាធម្មនុញ្ញបានប្រព្រឹត្តទៅស្របតាមមាត្រា ២១ នៃច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ ។ តំណាងរាជរដ្ឋាភិបាលឆ្លើយបញ្ជាក់ច្បាស់ថា ក្រុមប្រឹក្សាជាតិគណនេយ្យ « **ក.ជ.គ** » ស្ថិតនៅក្នុងអំណាចនីតិប្រតិបត្តិ
- យល់ឃើញថា ជំពូកទី១ ស្តីពីបទប្បញ្ញត្តិទូទៅ មាន ៤ មាត្រា គឺចាប់ពីមាត្រា ១ ដល់មាត្រា ៤ ចែងពីគោលបំណងគ្រប់គ្រង វិស័យគណនេយ្យ និងសវនកម្មប្រកបដោយប្រសិទ្ធភាព តម្លាភាព គណនេយ្យភាព និងភាពជឿទុកចិត្តបាន ព្រមទាំងគោលដៅ វិសាលភាពអនុវត្ត និងបច្ចេកស័ព្ទសំខាន់ៗដែលប្រើក្នុងច្បាប់នេះ ។ បទប្បញ្ញត្តិក្នុងមាត្រាទាំង ៤ នៃជំពូកទី១ នេះ ស្របនឹងជំពូកទី៥ នៃរដ្ឋធម្មនុញ្ញ
- យល់ឃើញថា ជំពូកទី២ ស្តីពីក្រុមប្រឹក្សាជាតិគណនេយ្យ មាន ៤ មាត្រា គឺចាប់ពីមាត្រា ៥ ដល់មាត្រា ៨ ចែងពីការបង្កើតក្រុមប្រឹក្សាជាតិគណនេយ្យ ដែលសរសេរជាអក្សរកាត់ **ក.ជ.គ** ។ សមាសភាព **ក.ជ.គ** មានអាណត្តិ ៥ ឆ្នាំ ត្រូវតែងតាំងដោយអនុក្រឹត្យតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។ មុខងារនិងភារកិច្ចរបស់ **ក.ជ.គ** ។ ការរៀបចំនិងការប្រព្រឹត្តទៅនៃ **ក.ជ.គ** ត្រូវកំណត់ដោយអនុក្រឹត្យ តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។ បទប្បញ្ញត្តិក្នុងមាត្រាទាំង ៤ នៃជំពូកទី២ នេះ ស្របនឹងជំពូកទី៥ នៃរដ្ឋធម្មនុញ្ញ លើកលែងតែត្រង់ចំណុចគ្រេទី៤ នៃមាត្រា ៧ ដែលចែងថា « *ពិនិត្យ និងដោះស្រាយបណ្តឹង ឬវិវាទពាក់ព័ន្ធនឹងគណនេយ្យ និងសវនកម្ម* » មិនស្របនឹងវាក្យខ័ណ្ឌទី៣ មាត្រា ១២៨ ថ្មី នៃរដ្ឋធម្មនុញ្ញដែលចែងថា « *អំណាចតុលាការគ្របដណ្តប់ទៅលើរឿងក្តីទាំងអស់ រួមទាំងរឿងក្តីរដ្ឋបាលផង* ។ » និងមាត្រា ១៣០ ថ្មី នៃរដ្ឋធម្មនុញ្ញដែលចែងថា «*គ្មានអង្គការណាមួយនៃអំណាចនីតិប្បញ្ញត្តិ ឬនីតិប្រតិបត្តិអាចទទួលអំណាចតុលាការអ្វីបានឡើយ ។*»

- យល់ឃើញថា ជំពូកទី៣ ស្តីពីស្ថាប័នវិជ្ជាជីវៈគណនេយ្យ និងសវនកម្ម មាន ២ មាត្រា គឺមាត្រា ៩ និងមាត្រា ១០ ចែងពីវិជ្ជាជីវៈគណនេយ្យ និងសវនកម្មនៃព្រះរាជាណាចក្រកម្ពុជា ត្រូវបានគ្រប់គ្រង និងគាំពារដោយស្ថាប័នវិជ្ជាជីវៈគណនេយ្យ និងសវនកម្មតែមួយគត់និងឯករាជ្យក្នុងវិជ្ជាជីវៈ ។ ការបង្កើត ការរៀបចំនិងការប្រព្រឹត្តទៅនៃស្ថាប័នវិជ្ជាជីវៈគណនេយ្យ និងសវនកម្ម ត្រូវកំណត់ដោយអនុក្រឹត្យ ។ បទប្បញ្ញត្តិក្នុងមាត្រាទាំង ២ នៃជំពូកទី៣ នេះ ស្របនឹងជំពូកទី៥ នៃរដ្ឋធម្មនុញ្ញ
- យល់ឃើញថា ជំពូកទី៤ ស្តីពីស្តង់ដាគណនេយ្យ មាន ១ មាត្រា គឺមាត្រា ១១ ចែងពីស្តង់ដាគណនេយ្យ ត្រូវសម្រេចដាក់ឱ្យអនុវត្តដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ តាមសំណើរបស់ **គ.ជ.គ** ។ ស្តង់ដាគណនេយ្យមានអានុភាពអនុវត្តចំពោះស្ថាប័នសាធារណៈ សហគ្រាស និងអង្គភាពមិនស្វែងរកប្រាក់ចំណេញ ។ បទប្បញ្ញត្តិក្នុងមាត្រា ១១ នៃជំពូកទី៤ នេះ ស្របនឹងជំពូកទី៥ នៃរដ្ឋធម្មនុញ្ញ
- យល់ឃើញថា ជំពូកទី៥ ស្តីពីស្តង់ដាសវនកម្ម មាន ១ មាត្រា គឺមាត្រា ១២ ចែងពីស្តង់ដាសវនកម្ម ត្រូវសម្រេចដាក់ឱ្យអនុវត្តដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ តាមសំណើរបស់ **គ.ជ.គ** ។ ស្តង់ដាសវនកម្មមានអានុភាពអនុវត្តចំពោះសវនករទាំងអស់ ដែលប្រកបវិជ្ជាជីវៈនៅព្រះរាជាណាចក្រកម្ពុជា ។ បទប្បញ្ញត្តិក្នុងមាត្រា ១២ នៃជំពូកទី៥ នេះ ស្របនឹងជំពូកទី៥ នៃរដ្ឋធម្មនុញ្ញ
- យល់ឃើញថា ជំពូកទី៦ ស្តីពីក្រមសីលធម៌វិជ្ជាជីវៈ មាន ៣ មាត្រា គឺចាប់ពីមាត្រា ១៣ ដល់មាត្រា ១៥ ចែងពីក្រមសីលធម៌សម្រាប់វិជ្ជាជីវៈគណនេយ្យករ និងសវនករ ដែលកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ តាមសំណើរបស់ **គ.ជ.គ** ។ សវនករមិនអាចផ្តល់សេវាសវនកម្មជូនសហគ្រាសឬអង្គភាពមិនស្វែងរកប្រាក់ចំណេញដែលខ្លួនធ្លាប់ផ្តល់សេវាគណនេយ្យឡើយ លើកលែងតែការផ្តល់សេវាគណនេយ្យនោះបានបញ្ចប់ទៅក្នុងរយៈពេលយ៉ាងតិចបីឆ្នាំ ។ សវនករមិនត្រូវបន្តផ្តល់សេវាកម្មជូនសហគ្រាស ឬអង្គភាពមិនស្វែងរកប្រាក់ចំណេញណាមួយលើសពីប្រាំឆ្នាំបន្តបន្ទាប់គ្នាឡើយ ។ សវនករមិនត្រូវផ្តល់សេវាសវនកម្មជូនសហគ្រាសដែលខ្លួនទទួលផលប្រយោជន៍ ឬមានសិទ្ធិគ្រប់គ្រង ទោះដោយផ្ទាល់ក្តី ឬដោយប្រយោលក្តី តាមរយៈសហព័ទ្ធ ញាតិលោហិត ឬញាតិពន្ធ រហូតដល់ថ្នាក់ទី៣ ។ បទប្បញ្ញត្តិក្នុងមាត្រាទាំង ៣ នៃជំពូកទី៦ នេះ ស្របនឹងជំពូកទី៥ នៃរដ្ឋធម្មនុញ្ញ
- យល់ឃើញថា ជំពូកទី៧ ស្តីពីកាតព្វកិច្ចរៀបចំរបាយការណ៍ហិរញ្ញវត្ថុ មាន ៨ មាត្រា គឺចាប់ពីមាត្រា

១៦ ដល់ មាត្រា ២៣ ចែងពីរបាយការណ៍ហិរញ្ញវត្ថុ រួមមានរបាយការណ៍នានាដែលត្រូវកំណត់ក្នុងស្តង់ដាគណនេយ្យ ។ របាយការណ៍ហិរញ្ញវត្ថុអាចតម្រូវឱ្យធ្វើសវនកម្មតាមលក្ខខណ្ឌដែលត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុតាមសំណើរបស់ **គ.ជ.គ** ។ របាយការណ៍ហិរញ្ញវត្ថុ ត្រូវធ្វើជាមូលដ្ឋានសម្រាប់ការបំពេញកាតព្វកិច្ចសារពើពន្ធ អនុលោមតាមច្បាប់ និងបទប្បញ្ញត្តិជាធរមាន ។ ស្ថាប័នសាធារណៈ សហគ្រាស និងអង្គភាពមិនស្វែងរកប្រាក់ចំណេញមានកាតព្វកិច្ចកាន់បញ្ជីគណនេយ្យ ។ បញ្ជីគណនេយ្យ និងរបាយការណ៍ហិរញ្ញវត្ថុ ត្រូវធ្វើជាភាសាខ្មែរ និងជាប្រាក់រៀល លើកលែងតែក្នុងកិច្ចប្រតិបត្តិការអន្តរជាតិជាប្រចាំ អាចប្រើជាភាសាអង់គ្លេស និងជារូបិយបណ្ណបរទេស អមជាមួយឯកសារខាងដើម ។ បទប្បញ្ញត្តិក្នុងមាត្រាទាំង ៨ នៃជំពូកទី៧ នេះ ស្របនឹងជំពូកទី៥ នៃរដ្ឋធម្មនុញ្ញ

- យល់ឃើញថា ជំពូកទី៨ ស្តីពីរបាយការណ៍សវនកម្ម មាន ៣ មាត្រា គឺចាប់ពីមាត្រា ២៤ ដល់មាត្រា ២៦ ចែងពីរបាយការណ៍សវនកម្មរួមមានរបាយការណ៍នានាដែលត្រូវកំណត់ក្នុងស្តង់ដាសវនកម្ម ។ របាយ-ការណ៍សវនកម្មត្រូវរៀបចំឡើងជាភាសាខ្មែរ ដែលអាចអមដោយភាសាអង់គ្លេសមកជាមួយ ។ ភស្តុតាងសវនកម្មត្រូវរក្សាទុកក្នុងរយៈពេល ១០ ( ដប់ ) ឆ្នាំ យ៉ាងតិចគិតចាប់ពីកាលបរិច្ឆេទចេញរបាយការណ៍សវនកម្ម ។ បទប្បញ្ញត្តិក្នុងមាត្រាទាំង ៣ នៃជំពូកទី៨ នេះ ស្របនឹងជំពូកទី៥ នៃរដ្ឋធម្មនុញ្ញ
- យល់ឃើញថា ជំពូកទី៩ ស្តីពីគណនេយ្យករ និងសវនករ មាន ២ មាត្រា គឺមាត្រា ២៧ និង មាត្រា ២៨ ចែងពីបុគ្គលគ្រប់រូប ទោះជារូបវន្តបុគ្គលក្តី នីតិបុគ្គលក្តី អាចជាគណនេយ្យករ និង/ឬ សវនករបាន លុះត្រាតែបានចុះឈ្មោះជាសមាជិករបស់ស្ថាប័នវិជ្ជាជីវៈគណនេយ្យ និងសវនកម្ម ។ ប្រភេទគណនេយ្យករ និងសវនករ ដែលជាសមាជិករបស់ស្ថាប័នវិជ្ជាជីវៈគណនេយ្យ និងសវនកម្ម ត្រូវកំណត់ដោយអនុក្រឹត្យស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃស្ថាប័នវិជ្ជាជីវៈគណនេយ្យ និងសវនកម្ម ។ ការប្រកបវិជ្ជាជីវៈគណនេយ្យ និង/ឬ សវនកម្មមានវិសមិតភាពជាមួយមុខងារសាធារណៈ និងមុខងារនយោបាយក្នុងអង្គការនីតិប្បញ្ញត្តិ អង្គការនីតិប្រតិបត្តិ និងមុខងារអង្គការតុលាការ ។ បទប្បញ្ញត្តិក្នុងមាត្រាទាំង ២ នៃជំពូកទី៩ នេះ ស្របនឹងជំពូកទី៥ នៃរដ្ឋធម្មនុញ្ញ
- យល់ឃើញថា ជំពូកទី១០ ស្តីពីអាជ្ញាបណ្ណ មាន ២ មាត្រា គឺមាត្រា ២៩ និង មាត្រា ៣០ ចែងពីបុគ្គលគ្រប់រូប ទោះជារូបវន្តបុគ្គលក្តី នីតិបុគ្គលក្តី អាចប្រកបវិជ្ជាជីវៈជាគណនេយ្យករ ឬ សវនករបាន លុះត្រាតែបានចុះឈ្មោះជាសមាជិករបស់ស្ថាប័នវិជ្ជាជីវៈគណនេយ្យ និងសវនកម្ម និងទទួលបានអាជ្ញាបណ្ណ

ពី **គ.ជ.គ** ។ អាជ្ញាបណ្ណចែកចេញជា ២ (ពីរ) ប្រភេទ គឺអាជ្ញាបណ្ណប្រកបវិជ្ជាជីវៈគណនេយ្យ និង អាជ្ញាបណ្ណប្រកបវិជ្ជាជីវៈសវនកម្ម ។ លក្ខខណ្ឌ និង នីតិវិធីនៃការផ្តល់អាជ្ញាបណ្ណ ត្រូវកំណត់ដោយ ប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុតាមសំណើរបស់ **គ.ជ.គ** ។ បទប្បញ្ញត្តិក្នុងមាត្រា ទាំង ២ នៃជំពូកទី១០ នេះ ស្របនឹងជំពូកទី៥ នៃរដ្ឋធម្មនុញ្ញ

- យល់ឃើញថា ជំពូកទី១១ ស្តីពីទោសប្បញ្ញត្តិ មាន ៧ មាត្រា គឺចាប់ពីមាត្រា ៣១ ដល់មាត្រា ៣៧ ចែងពីទណ្ឌកម្មដែលត្រូវដាក់លើរូបវន្តបុគ្គល និង នីតិបុគ្គលប្រព្រឹត្តផ្ទុយនឹងក្រមសីលធម៌វិជ្ជាជីវៈរបស់ គណនេយ្យករ និងសវនករ ។ ទោសប្បញ្ញត្តិចំពោះការប្រកបវិជ្ជាជីវៈគណនេយ្យ ឬ សវនកម្មដោយគ្មាន អាជ្ញាបណ្ណ ការក្លែងរបាយការណ៍សវនកម្ម ការមិនប្តឹងបរិហារពីបទល្មើសនៅក្នុងក្របខ័ណ្ឌនៃមុខងារ ឬនៅក្នុងឱកាសនៃការបំពេញមុខងាររបស់ខ្លួន ។ បទប្បញ្ញត្តិក្នុងមាត្រាទាំង ៧ នៃជំពូកទី១១ នេះ ស្របនឹងជំពូកទី៥ នៃរដ្ឋធម្មនុញ្ញ
- យល់ឃើញថា ជំពូកទី១២ ស្តីពីអន្តរប្បញ្ញត្តិ មាន ១ មាត្រា គឺមាត្រា ៣៨ ចែងពីលិខិតបទដ្ឋាន គតិយុត្តទាំងឡាយដែលបានដាក់ឱ្យអនុវត្ត ដោយផ្អែកលើមូលដ្ឋាននៃច្បាប់ស្តីពីគណនេយ្យសហគ្រាស សវនកម្មគណនេយ្យសហគ្រាស និងវិជ្ជាជីវៈគណនេយ្យដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៧០២/០១១ ចុះថ្ងៃទី ០៨ ខែ កក្កដា ឆ្នាំ២០០២ ត្រូវបន្តអានុភាពគតិយុត្តរហូតដល់មាន បទប្បញ្ញត្តិថ្មីមកជំនួស ។ បទប្បញ្ញត្តិក្នុងមាត្រា ៣៨ នៃជំពូកទី១២ នេះ ស្របនឹងរដ្ឋធម្មនុញ្ញ
- យល់ឃើញថា ជំពូកទី១៣ ស្តីពីអវសានប្បញ្ញត្តិ មាន ១ មាត្រា គឺមាត្រា ៣៩ ចែងពីច្បាប់ស្តីពី គណនេយ្យសហគ្រាស សវនកម្មគណនេយ្យសហគ្រាស និងវិជ្ជាជីវៈគណនេយ្យដែលប្រកាសឱ្យប្រើ ដោយព្រះរាជក្រមលេខ នស/រកម/០៧០២/០១១ ចុះថ្ងៃទី ០៨ ខែ កក្កដា ឆ្នាំ២០០២ និងបទប្បញ្ញត្តិ ទាំងឡាយណាដែលផ្ទុយនឹងច្បាប់នេះ ត្រូវទុកជានិរាករណ៍ ។ បទប្បញ្ញត្តិក្នុងមាត្រា ៣៩ នៃជំពូកទី១៣ នេះ ស្របនឹងរដ្ឋធម្មនុញ្ញ
- យល់ឃើញថា ខ្លឹមសារទាំង ១៣ ជំពូក ៣៩ មាត្រា នៃច្បាប់ស្តីពីគណនេយ្យ និងសវនកម្ម ស្របនឹង រដ្ឋធម្មនុញ្ញ លើកលែងតែចំណុចត្រៃទី៤ នៃមាត្រា ៧ ។

## សម្រេច

**មាត្រា ១.** ច្បាប់ស្តីពីគណនេយ្យ និងសវនកម្ម ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី ១៤ ខែ មករា ឆ្នាំ២០១៦ នាសម័យប្រជុំរដ្ឋសភាលើកទី៥ នីតិកាលទី៥ និង ព្រឹទ្ធសភាបានពិនិត្យ និងឱ្យយោបល់ឯកភាព

ទាំងស្រុងលើទម្រង់ និងគតិច្បាប់ ដោយឥតកែប្រែ ក្នុងសម័យប្រជុំលើកទី៨ នីតិកាលទី៣ នាថ្ងៃទី ០៥ ខែ កុម្ភៈ ឆ្នាំ២០១៦ ត្រូវបានប្រកាសថា ស្របនឹងរដ្ឋធម្មនុញ្ញ លើកលែងតែចំណុចត្រៃទី៤ នៃមាត្រា ៧។

**មាត្រា ២.-** សេចក្តីសម្រេចនេះ ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៣ ខែ មីនា ឆ្នាំ២០១៦ ក្នុងកិច្ចប្រជុំពេញអង្គនៃក្រុមប្រឹក្សាធម្មនុញ្ញ ជាសេចក្តីសម្រេចស្ថាពរ បិទផ្លូវតវ៉ា ហើយមានអានុភាពអនុវត្តទៅលើអំណាចទាំងអស់ដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ និង ត្រូវចុះផ្សាយក្នុងរាជកិច្ច ។

រាជធានីភ្នំពេញ ថ្ងៃទី ០៣ ខែ មីនា ឆ្នាំ២០១៦

ជ.ក្រុមប្រឹក្សាធម្មនុញ្ញ

ប្រធាន

ឯក សំអុល

តមកពីរាជកិច្ចលេខ ១-១៨

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ: ១៧១ អនក្រ.បក**

**អនុក្រឹត្យ**

**ស្តីពី**

**ការដាក់ឱ្យអនុវត្តកម្មវិធីកាត់បន្ថយនិង/ឬលុបបំបាត់ពន្ធគយរបស់ព្រះរាជាណាចក្រកម្ពុជា ស្របតាមនាមវលីនៃតារាងពន្ធគយសុខដុមរបស់អាស៊ាន ឆ្នាំ២០១២ ក្រោមកិច្ចព្រមព្រៀងពាណិជ្ជកម្មទំនិញអាស៊ាន**

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០២៩៧/០៣ ចុះថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសារពើពន្ធ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៧/០១៧ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីគយ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៩០៤/០០២ ចុះថ្ងៃទី០៩ ខែកញ្ញា ឆ្នាំ២០០៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការអនុម័តយល់ព្រមលើពិធីសារនៃការចូលរួមរបស់ព្រះរាជាណាចក្រកម្ពុជា ក្នុងអង្គការពាណិជ្ជកម្មពិភពលោក
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០៩/០១៧ ចុះថ្ងៃទី២៩ ខែសីហា ឆ្នាំ២០០៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀងពាណិជ្ជកម្មទំនិញអាស៊ាន

- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៣/០០៤ ចុះថ្ងៃទី២០ ខែមករា ឆ្នាំ២០០៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការអនុម័តយល់ព្រមឱ្យព្រះរាជាណាចក្រកម្ពុជាចូលរួមក្នុងអនុសញ្ញាស្តីពីការបង្កើតក្រុមប្រឹក្សាសហប្រតិបត្តិការគយ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៣/០០១ ចុះថ្ងៃទី២០ ខែមករា ឆ្នាំ២០០៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការអនុម័តយល់ព្រមឱ្យព្រះរាជាណាចក្រកម្ពុជាចូលរួមក្នុងអនុសញ្ញាស្តីពីការធ្វើឱ្យស៊ីចង្វាក់គ្នានៃការកំណត់មុខទំនិញនិងប្រព័ន្ធលេខកូដ
នីតិវិធីលម្អិតសម្រាប់ការប្រើប្រាស់មូលនិធិខាងលើ ត្រូវកំណត់ដោយប្រកាសរួមរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុនិងប្រធានអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន។

**មាត្រា៩ .-**

ក្រសួង ស្ថាប័ន អង្គភាព ឬអង្គការឯកទេសនានាដែលមានបំណងទទួលមូលនិធិរបស់អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ត្រូវដាក់ពាក្យសុំមកអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ដោយភ្ជាប់មកជាមួយនូវព័ត៌មានលម្អិត ដែលកំណត់ដោយអគ្គលេខាធិការដ្ឋាននៃអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន។

ក្នុងករណីសំណើវិភាគទានត្រូវបានអនុញ្ញាត អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ត្រូវថតចម្លងឯកសារមួយច្បាប់ជូនមកក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

## ជំពូកទី៥
## ការតាមដានការប្រមូលមូលនិធិ

**មាត្រា១០ .-**

មន្ត្រីនគរបាលយុត្តិធម៌ ដែលដឹកនាំកិច្ចប្រតិបត្តិការបង្ក្រាបបទល្មើសគ្រឿងញៀន ត្រូវធ្វើបញ្ជីមកអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀននិងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រាល់មុខសញ្ញាដែលជាប្រភពនៃមូលនិធិពាក់ព័ន្ធបទល្មើសគ្រឿងញៀន។

**មាត្រា១១ .-**

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុត្រូវបង្កើតយន្តការអន្តរក្រសួង ស្ថាប័នមួយ ដើម្បីប្រមូល គ្រប់គ្រង និងចាត់ចែងមូលនិធិដូចមានចែងនៅក្នុងមាត្រាខាងលើនេះ។

អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀនឬតំណាងស្របច្បាប់ ត្រូវចូលរួមនៅក្នុងដំណើរការយន្តការនេះ ដើម្បីធានាថាការប្រមូល ការគ្រប់គ្រង និងការចាត់ចែងមូលនិធិខាងលើនេះ ប្រកបដោយប្រសិទ្ធភាព តម្លាភាព និងគណនេយ្យភាព។

យន្តការខាងលើនេះត្រូវបង្កើតឡើងដោយប្រកាសរួមរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុនិងប្រធានអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន។

## ជំពូកទី៦
## ប្រភពចំណូលនៃមូលនិធិ

**មាត្រា១២ .-**

មូលនិធិជាតិសម្រាប់ការប្រយុទ្ធប្រឆាំងគ្រឿងញៀនទទួលបានមកពី៖

- ថវិការដ្ឋដែលផ្តល់ឲ្យតាមរយៈប្រកាសរួមរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុនិងប្រធានអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ដែលមានប្រភពមកពីទ្រព្យសម្បត្តិជាសាច់ប្រាក់ដែលត្រូវបានរឹបអូសពីបទល្មើសគ្រឿងញៀន រួមទាំងផលទុនឬទ្រព្យសម្បត្តិដែលជាផលកើតចេញពីបទល្មើសគ្រឿងញៀន និងប្រាក់ដែលបានមកពីការលក់វត្ថុ ការចាត់ចែង ឬទ្រព្យសម្បត្តិដែលត្រូវបានរឹបអូស ស្របតាមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន
- អំណោយឬជំនួយថវិកា សម្ភារៈ ឧបករណ៍នានាពីសប្បុរសជន ស្ថាប័នជាតិនិងអន្តរជាតិនានាដែលជាប្រភពស្របច្បាប់។/.

## ជំពូកទី៧
## អវសានប្បញ្ញត្តិ

**មាត្រា១៣ .-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះត្រូវទុកជានិរាករណ៍។

**មាត្រា១៤ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ប្រធានអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី០៧ ខែ មីនា ឆ្នាំ២០១៦

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន

សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី សូមហត្ថលេខា

**ឧបនាយករដ្ឋមន្ត្រី**

**ប្រធានអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន**

**កែ គឹមយ៉ាន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា១៤
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ:...៣៤...អនក្រ.បក

## អនុក្រឹត្យ

ស្តីពី

## ការកែសម្រួលតួនាទីនិងភារកិច្ចរបស់ក្រសួងបរិស្ថាន និងរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ពាក់ព័ន្ធនឹងសម្បទានដីសេដ្ឋកិច្ចនិងការគ្រប់គ្រងតំបន់វិនិយោគអភិវឌ្ឍន៍សម្បទានដីសេដ្ឋកិច្ច និងការគ្រប់គ្រងតំបន់ការពារ និងអភិរក្សព្រៃឈើ និងជលផល

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងបរិស្ថាន
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២៩៦/៣៦ ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០០២ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០២/០១៦ ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០០២ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីព្រៃឈើ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៦/០១១ ចុះថ្ងៃទី២១ ខែឧសភា ឆ្នាំ២០០៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីជលផល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០២០៨/០០៧ ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីតំបន់ការពារធម្មជាតិ
- បានឃើញព្រះរាជក្រឹត្យចុះថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ១៩៩៣ ស្តីពីកាបង្កើតនិងការកំណត់តំបន់ការពារធម្មជាតិ
- បានឃើញអនុក្រឹត្យលេខ ១៧ អនក្រ.បក ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ ៥៥ អនក្រ.បក ចុះថ្ងៃទី០៤ ខែឧសភា ឆ្នាំ២០១៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងបរិស្ថាន
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងបរិស្ថាន និងរដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទ

## សម្រេច

**មាត្រា ១.-**

ត្រូវបានកែសម្រួលតួនាទី និងភារកិច្ចរបស់ក្រសួងបរិស្ថាន និងរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ពាក់ព័ន្ធនឹងសមត្ថកិច្ចនិងការគ្រប់គ្រងតំបន់វិនិយោគអភិវឌ្ឍន៍សម្បទានដីសេដ្ឋកិច្ច និងសមត្ថកិច្ចនិងការគ្រប់គ្រងតំបន់ការពារ និងអភិរក្សព្រៃឈើ និងជលផល ដូចខាងក្រោម÷

១-ត្រូវបានផ្ទេរតំបន់វិនិយោគអភិវឌ្ឍន៍សម្បទានដីសេដ្ឋកិច្ចទាំងអស់ ដែលស្ថិតក្រោមសមត្ថកិច្ច និងការគ្រប់គ្រងរបស់ក្រសួងបរិស្ថានឱ្យស្ថិតក្រោមសមត្ថកិច្ចនិងការគ្រប់គ្រងរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

២-ត្រូវបានផ្ទេរតំបន់ការពារ និងអភិរក្សព្រៃឈើ និងជលផលទាំងអស់ដែលស្ថិតក្រោមសមត្ថកិច្ចនិងការគ្រប់គ្រងរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ឱ្យស្ថិតក្រោមសមត្ថកិច្ចនិងការគ្រប់គ្រងរបស់ក្រសួងបរិស្ថាន។

**មាត្រា២. -**

ប្រគល់ភារកិច្ចជូនរដ្ឋមន្ត្រីក្រសួងបរិស្ថាន ដឹកនាំការងាររៀបចំធ្វើវិសោធនកម្មជាបន្ទាន់លើបទប្បញ្ញត្តិច្បាប់ ដែលមានការពាក់ព័ន្ធ សម្រាប់ដាក់ឆ្លងគណៈរដ្ឋមន្ត្រីពិនិត្យនិងសម្រេច ដើម្បីបញ្ជូនទៅស្ថាប័ននីតិបញ្ញត្តិពិនិត្យ និងផ្តល់ការអនុម័តជាកិច្ចការប្រញាប់។

ប្រគល់ភារកិច្ចជូនរដ្ឋមន្ត្រីក្រសួងបរិស្ថាន ដឹកនាំការងាររៀបចំធ្វើវិសោធនកម្មជាបន្ទាន់ លើបទប្បញ្ញត្តិព្រះរាជក្រឹត្យដែលមានការពាក់ព័ន្ធ សម្រាប់ដាក់ឆ្លងគណៈរដ្ឋមន្ត្រីពិនិត្យនិងសម្រេច ដើម្បីក្រាបបង្គំទូលថ្វាយព្រះមហាក្សត្រ សូមទ្រង់ពិនិត្យនិងសម្រេច ឡាយព្រះហស្តលេខា។

**មាត្រា ៣.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងរដ្ឋមន្ត្រីគ្រប់ក្រសួង ប្រធានគ្រប់ស្ថាប័នពាក់ព័ន្ធ ត្រូវអនុវត្តអនុក្រឹត្យនេះឱ្យមានប្រសិទ្ធភាពខ្ពស់ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៤ ខែ មីនា ឆ្នាំ ២០១៦

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល÷**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- គ្រប់សាលារាជធានី-ខេត្ត
- ដូចមាត្រា ៣
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

បានយកសេចក្តីគោរពជម្រាបជូន

**សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី** សូមហត្ថលេខា

**រដ្ឋមន្ត្រី**
**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

**អ៊ុក រ៉ាប៊ុន**

**រដ្ឋមន្ត្រី**
**ក្រសួងបរិស្ថាន**

**សាយ សំអាល់**

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ...៣៤...អនក្រ.បក

# អនុក្រឹត្យ

## ស្ដីពី

## ការកែសម្រួលអត្រាអាករនាំចេញលើមុខទំនិញកៅស៊ូ

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំនិងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០២៩៧/០៣ ចុះថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីសារពើពន្ធ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៧/០១៧ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីគយ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៥/០១៦ ចុះថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០១៥ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៦
- បានឃើញអនុក្រឹត្យលេខ ១៧២ អនក្រ.បក ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០១០ ស្ដីពីការកែសម្រួលអត្រាអាករពិសេស និងអត្រាអាករនាំចេញលើទំនិញមួយចំនួន
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដើម្បីលើកស្ទួយឧស្សាហកម្មកៅស៊ូនាំចេញ

**<u>សម្រេច</u>**

**មាត្រា១.-**

ត្រូវបានកែសម្រួលអត្រាអាករនាំចេញដែលគិតតាមរបៀប “ពន្ធគិតតាមឯកតា” លើមុខទំនិញជ័រកៅស៊ូ ដូចមានចែងក្នុងមាត្រា ៣ នៃអនុក្រឹត្យលេខ ១៧២ អនក្រ.បក ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០១០ ដូចខាងក្រោម÷

- ពុំជាប់អាករនាំចេញ បើតម្លៃគិតអាករនាំចេញទាបជាង ១០០០ ដុល្លារអាមេរិកក្នុង ១ តោន
- ជាប់អាករនាំចេញ ៥០ ដុល្លារអាមេរិកក្នុង ១ តោន បើតម្លៃគិតអាករនាំចេញចាប់ពី ១០០០ តែទាបជាង ២០០០ ដុល្លារអាមេរិកក្នុង ១ តោន
- ជាប់អាករនាំចេញ ១៥០ ដុល្លារអាមេរិកក្នុង ១ តោន បើតម្លៃគិតអាករនាំចេញចាប់ពី ២០០០ តែទាបជាង ៣០០០ ដុល្លារអាមេរិកក្នុង ១ តោន
- ជាប់អាករនាំចេញ ២០០ ដុល្លារអាមេរិកក្នុង ១ តោន បើតម្លៃគិតអាករនាំចេញចាប់ពី ៣០០០ តែទាបជាង ៤០០០ ដុល្លារអាមេរិកក្នុង ១ តោន
- ជាប់អាករនាំចេញ ៣០០ ដុល្លារអាមេរិកក្នុង ១ តោន បើតម្លៃគិតអាករនាំចេញចាប់ពី ៤០០០ ដុល្លារអាមេរិកក្នុង ១ តោន ឡើងទៅ។

**មាត្រា២.-**

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីអនុក្រឹត្យនេះត្រូវចាត់ទុកជានិរាករណ៍។

**មាត្រា ៣.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកចាត់ចែងអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃទី ០១ ខែមីនា ឆ្នាំ ២០១៦ តទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៤ ខែ មីនា ឆ្នាំ ២០១៦

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោហ៊ុន សែន**

បានយកសេចក្តីជម្រាបជូន

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា**

សូមហត្ថលេខា

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**បណ្ឌិត អូន ព័ន្ធមុនីរ័ត្ន**

**កន្លែងទទួល៖**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោហ៊ុនសែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា
- ដូចមាត្រា ៣ "ដើម្បីអនុវត្ត"
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ :**...៣៦...អនក្រ.បក

**អនុក្រឹត្យ**

**ស្តីពី**

**ការផ្ទេរឥណទានថវិកា**

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៥/០១៦ ចុះថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០១៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៦
- បានឃើញអនុក្រឹត្យលេខ ៤៨៨អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១៨៣អនក្រ.បក ចុះថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០១៥ ស្តីពីការបែងចែកឥណទានចំណាយថវិកាថ្នាក់ជាតិតាមជំពូកនៃច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៦
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

**សម្រេច**

**មាត្រា១.–**

ត្រូវបានអនុញ្ញាតឱ្យផ្ទេរឥណទានថវិកាចំនួន ១៩៤ ០០០ ០០០ រៀល (មួយរយកៅសិបបួនលានរៀលគត់) ពីជំពូក ៦៩ (ចំណាយមិនបានគ្រោងទុក) នៃខ្ទង់ចំណាយមិនទាន់បែងចែកមកជំពូក ៦៥ (ឧបត្ថម្ភធន) ជូនក្រសួងសាធារណការ និងដឹកជញ្ជូន សម្រាប់ការគ្រប់គ្រងឆ្នាំ ២០១៦។

**មាត្រា២.–**

ការបែងចែកឥណទានថវិកាចំណាយផ្ទេរក្នុងជំពូកនេះតាមគណនីនិងអនុគណនី ត្រូវធ្វើឡើងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សម្រាប់បង់វិភាគទានជូនអង្គការនាវាចរណ៍សមុទ្រអន្តរជាតិប្រចាំឆ្នាំ ២០១៦។

**មាត្រា៣.–**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងសាធារណការនិងដឹកជញ្ជូន ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ ៣ ឆ្នាំ ២០១៦

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន

សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រីសូមហត្ថលេខា

**រដ្ឋមន្ត្រី**

**ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**អូន ព័ន្ធមុនីរ័ត្ន**

**កន្លែងទទួល:**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តម/លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៣
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ:...៣៧...អនក្រ.បក

**អនុក្រឹត្យ**

**ស្តីពី**

**ការកែសម្រួលនិងការដំឡើងប្រាក់បំណាច់មុខងារ**
**ជូនយោធិននៃកងយោធពលខេមរភូមិន្ទ**

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៧ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការពារជាតិ
- បានឃើញព្រះរាជក្រមលេខ ជស/រកម/១១៩៧/០៥ ចុះថ្ងៃទី៦ ខែវិច្ឆិកា ឆ្នាំ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីលក្ខន្តិកៈទូទៅចំពោះយោធិននៃកងយោធពលខេមរភូមិន្ទ
- បានឃើញអនុក្រឹត្យលេខ១៧ អនក្រ.បក ចុះថ្ងៃទី២៥ ខែមេសា ឆ្នាំ១៩៩៦ ស្តីពីការកែសំរួលប្រព័ន្ធបៀវត្សរបស់កងយោធពលខេមរភូមិន្ទ
- បានឃើញអនុក្រឹត្យលេខ១៤ អនក្រ.បក ចុះថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០១៥ ស្តីពីការកែសម្រួលបៀវត្សមូលដ្ឋាននិងការបើកផ្តល់បៀវត្សដល់យោធិននៃកងយោធពលខេមរភូមិន្ទ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងរដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ

**សម្រេច**

**មាត្រា១ .-**

អនុក្រឹត្យនេះមានគោលបំណងកែសម្រួល និង ដំឡើងប្រាក់បំណាច់មុខងារជូនយោធិននៃកងយោធពលខេមរភូមិន្ទ ដើម្បីធានាបាននូវសមធម៌ សង្គតិភាព ប្រសិទ្ធភាព និងការបង្កើនផលិតភាពការងារ។

**មាត្រា២ ._**

អនុក្រឹត្យនេះមានគោលដៅរៀបចំការកែសម្រួល និង ការដំឡើងប្រាក់បំណាច់មុខងាររបស់យោធិននៃកងយោធពលខេមរភូមិន្ទ។

**មាត្រា៣ ._**

អនុក្រឹត្យនេះមានវិសាលភាពអនុវត្តចំពោះយោធិននៃកងយោធពលខេមរភូមិន្ទ។

**មាត្រា៤ ._**

ប្រាក់បំណាច់មុខងាររបស់យោធិននៃកងយោធពលខេមរភូមិន្ទ ត្រូវបានរៀបចំបែងចែកតាមលំដាប់នៃមុខតំណែងមូលដ្ឋាននិងមុខតំណែងសមមូលជា១៦(ដប់ប្រាំមួយ)ថ្នាក់ ដូចមានក្នុងតារាងខាងក្រោម៖

| ល.រ | មុខតំណែងមូលដ្ឋាន | ប្រាក់បំណាច់មុខងារ(រៀល) |
|---|---|---|
| ១ | អគ្គមេបញ្ជាការ | ១ ៧៥០ ០០០ |
| ២ | អគ្គមេបញ្ជាការរង | ១ ៥០០ ០០០ |
| ៣ | មេបញ្ជាការ យោធភូមិភាគ | ១ ៣០០ ០០០ |
| ៤ | មេបញ្ជាការ កងពលធំ (ឬរងយោធភូមិភាគ) | ៧០០ ០០០ |
| ៥ | មេបញ្ជាការ កងពលតូច (ឬរងកងពលធំ) | ៦០០ ០០០ |
| ៦ | មេបញ្ជាការ កងវរសេនាធំ (ឬរងកងពលតូច) | ៤២០ ០០០ |
| ៧ | មេបញ្ជាការ កងវរសេនាតូច (ឬរងកងវរសេនាធំ) | ៣១០ ០០០ |
| ៨ | មេបញ្ជាការរង កងវរសេនាតូច | ២៥០ ០០០ |
| ៩ | មេបញ្ជាការ កងអនុសេនាធំ | ២១០ ០០០ |
| ១០ | មេបញ្ជាការរង កងអនុសេនាធំ | ១៩០ ០០០ |
| ១១ | មេបញ្ជាការ កងអនុសេនាតូច | ១៨០ ០០០ |
| ១២ | មេបញ្ជាការរង កងអនុសេនាតូច | ១៧០ ០០០ |
| ១៣ | នាយក្រុម | ១៦៥ ០០០ |
| ១៤ | នាយរងក្រុម | ១៦០ ០០០ |
| ១៥ | នាយពួក | ១៥៥ ០០០ |
| ១៦ | យុទ្ធជន | ១៥០ ០០០ |

ប្រាក់បំណាច់មុខងារខាងលើ ត្រូវអនុវត្តចាប់ពីថ្ងៃទី១ ខែមេសា ឆ្នាំ២០១៦តទៅ។

**មាត្រា៥ ._**

មុខតំណែងដ៏ទៃទៀតដែលសមមូលនឹងមុខតំណែងមូលដ្ឋានខាងលើ ត្រូវកំណត់ដោយប្រកាសរបស់ក្រសួងការពារជាតិ ផ្អែកលើព្រះរាជក្រឹត្យ អនុក្រឹត្យ ប្រកាសស្តីពីការតែងតាំង។

**មាត្រា៦ ._**

យោធិនដែលកំពុងស្ថិតក្នុងមុខតំណែងណាមួយ ត្រូវទទួលប្រាក់បំណាច់មុខងារក្នុងតំណែងនោះ។ ករណីយោធិនដែលកាន់មុខតំណែងច្រើន ត្រូវអនុញ្ញាតឱ្យជ្រើសរើសយកប្រាក់បំណាច់មុខងារតែមួយគត់។

**មាត្រា៧ .-**

ការកែប្រែចំនួនមុខតំណែងមូលដ្ឋានឬប្រាក់បំណាច់មុខងារដែលមានចែងក្នុងមាត្រា៤នៃអនុក្រឹត្យនេះ ត្រូវកំណត់ដោយអនុក្រឹត្យ។

**មាត្រា៨ .-**

យោធិនដែលមានសិទ្ធទទួលប្រាក់បំណាច់មុខងារ ត្រូវស្ថិតក្នុងលក្ខខណ្ឌដូចខាងក្រោម៖

- កំពុងបំពេញការងារក្នុងកងយោធពលខេមរភូមិន្ទ
- កំពុងផ្លាស់ប្តូរកន្លែងធ្វើការនិងកំពុងធ្វើដំណើរទៅកាន់មុខតំណែងនៅក្នុងឬក្រៅប្រទេស
- កំពុងបំពេញការសិក្សាក្នុងឬក្រៅប្រទេសតាមតម្រូវការរបស់កងទ័ព
- យោធិនពលី មរណៈ ពិការ និវត្តជន បាត់បង់សមត្ថភាពការងារដែលមិនទាន់ផ្ទេរទៅឱ្យក្រសួងទទួលបន្ទុកអតីតយុទ្ធជនគ្រប់គ្រងបន្ត
- យោធិនដែលទទួលការអនុញ្ញាតច្បាប់ក្នុងធុរៈផ្ទាល់ រយៈពេលសម្រាកព្យាបាលជម្ងឺ និងបាត់ខ្លួនក្នុងបេសកកម្ម។

**មាត្រា៩ .-**

ការបញ្ឈប់ការបើកផ្តល់ប្រាក់បំណាច់មុខងារ ត្រូវអនុវត្តចាប់ពីកាលបរិច្ឆេទកំណត់ក្នុងប្រកាសរបស់រដ្ឋមន្ត្រីក្រសួងការពារជាតិ ក្នុងករណីដូចខាងក្រោម៖

- យោធិនដែលសុំលាឈប់ពីការងារដោយមានការអនុញ្ញាត
- យោធិនដែលមានប្រកាសបណ្តេញចេញពីកងយោធពលខេមរភូមិន្ទ
- យោធិនដែលអវត្តមានគ្មានការអនុញ្ញាតឬហួសកំណត់ដោយសម្អាងលើប្រធានស័ក្តិដែលមិនសមស្រប
- យោធិនពលី មរណៈ ពិការ និវត្តជន បាត់បង់សមត្ថភាពការងារដែលបានផ្ទេរទៅឱ្យក្រសួងទទួលបន្ទុកអតីតយុទ្ធជនគ្រប់គ្រងបន្តរួចហើយ
- យោធិនដែលបាត់បង់ឋានន្តរស័ក្តិតាមសាលក្រមឬសាលដីកាស្ថាពររបស់តុលាការ។

**មាត្រា១០ .-**

របបឧបត្ថម្ភផ្សេងៗរបស់យោធិនក្រៅពីប្រាក់បំណាច់មុខងារ ត្រូវបន្តអនុវត្តហូតដល់មានការកែប្រែជាថ្មី។

**មាត្រា១១ .-**

អនុក្រឹត្យលេខ១៨៩ អនក្រ.បក ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០០៨ ស្តីពីការផ្តល់ប្រាក់បំណាច់មុខងារជូនកងយោធពលខេមរភូមិន្ទ អនុក្រឹត្យលេខ១៧៨ អនក្រ.បក ចុះថ្ងៃទី១៩ ខែតុលា ឆ្នាំ២០០៩ ស្តីពីការកែសម្រួលការផ្តល់ប្រាក់បំណាច់មុខងារជូនកងយោធពលខេមរភូមិន្ទនិងមន្ត្រីនគរបាលជាតិ និងអនុក្រឹត្យលេខ៣២ អនក្រ.បក ចុះថ្ងៃទី១៥ ខែមីនា ឆ្នាំ២០១០ ស្តីពីការកែសម្រួលការផ្តល់ប្រាក់បំណាច់មុខងារជូនកងយោធពលខេមរភូមិន្ទនិងមន្ត្រីនគរបាលជាតិ ត្រូវទុកជានិរាករណ៍ចាប់ពីថ្ងៃទី១ ខែមេសា ឆ្នាំ២០១៦។

**មាត្រា១២.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីគ្រប់ក្រសួងនិងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៩ ខែ មីនា ឆ្នាំ២០១៦

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន

សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី សូមហត្ថលេខា

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងការពារជាតិ**

**នាយឧត្តមសេនីយ៍ ទៀ បាញ់**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**អូន ព័ន្ធមុនីរ័ត្ន**

**រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ**

**ពេជ្រ ប៊ុនធិន**

**កន្លែងទទួល:**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា១២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ១៥៧ អនក្រ.តត

# អនុក្រឹត្យ

## ស្តីពីការជូនមេដាយស្ថាបនាជាតិ

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ

## សម្រេច

**មាត្រា ១.-** បំពាក់ **មេដាយស្ថាបនាជាតិ** តាមលំដាប់ថ្នាក់ ចំនួន ១៧គ្រឿង ប្រគេនព្រះសង្ឃ និងសប្បុរសជនចំនួន ១៧រូប ដែលមានស្នាដៃល្អក្នុងការចូលរួមជួយកសាងសមិទ្ធផលនានា នៅវត្តទីបត្យារាម ស្ថិតនៅភូមិជួរកណ្តាល ឃុំកោះពីរ ស្រុកក្រូចឆ្មារ ខេត្តត្បូងឃ្មុំ ដូចមានរាយនាមខាងក្រោម៖

**ក-មេដាយមាសស្ថាបនាជាតិ**

| | | |
|---|---|---|
| ១- | ឧកញ៉ា **ឌី ចណ្ណា** | សប្បុរសជន |
| ២- | ភិក្ខុ **ហ៊ាង ស៊ាងហេង** | គ្រូសូត្រស្តាំ |
| ៣- | ភិក្ខុ **យាន ម៉េងហួរ** | គ្រូសូត្រឆ្វេង |
| ៤- | លោក **ឌី ពេជ្រ** | សប្បុរសជន |
| ៥- | លោកស្រី **សោភ័ណ្ឌ មុន្នី** | សប្បុរសជន |
| ៦- | ឧបាសក **អ៊ី ខោល** | សប្បុរសជន |
| ៧- | ឧបាសិកា **ហ៊ុយ យូរ** | សប្បុរសជន |
| ៨- | ឧបាសិកា **ឡុច ស៊ីម** | សប្បុរសជន |
| ៩- | លោក **ហ៊ាង ចៅស៊ាង** | សប្បុរសជន |
| ១០- | លោក **ឆេង ពៅ** | សប្បុរសជន |
| ១១- | លោក **តាំង ម៉េងអ៊ាវ** | សប្បុរសជន |
| ១២- | លោក **ហ៊ាង ទិបុល** | សប្បុរសជន |
| ១៣- | លោក **ហ៊ាង សួយ** | សប្បុរសជន |

១៤- លោក **អ៊ា ពេងសាយ** សប្បុរសជន

**ខ-មេដាយប្រាក់ស្ថាបនាជាតិ**

១- លោក **គង់ ស្រ៊ាន** សប្បុរសជន

២- លោក **ហួយ ចំរើន** សប្បុរសជន

**គ-មេដាយសំរឹទ្ធស្ថាបនាជាតិ**

- លោក **ឆេង ហុង** សប្បុរសជន

**មាត្រា ២.**-រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ និងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី០១ ខែ កុម្ភៈ ឆ្នាំ ២០១៦

**នាយករដ្ឋមន្ត្រី**

**សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល:**
- -ក្រសួងព្រះបរមរាជវាំង
- -អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- -អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- -អគ្គលេខាធិការដ្ឋានរដ្ឋសភា
- -អគ្គលេខាធិការរាជរដ្ឋាភិបាល
- -ខុទ្ទកាល័យសម្ដេចនាយករដ្ឋមន្ត្រី
- -ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- -ដូចមាត្រា១ និងមាត្រា២
- -រាជកិច្ច
- -ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
លេខ:១៥៧ អនក្រ.បក

## អនុក្រឹត្យ
## ស្តីពីការជូនមេដាយការងារ

**រាជរដ្ឋាភិបាល**

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
-តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ

**សម្រេច**

**មាត្រា ១.**_ បំពាក់ **មេដាយការងារ** តាមលំដាប់ថ្នាក់ ចំនួន២០គ្រឿង ជូនមន្ត្រីរាជការ ចំនួន២០រូប ដែលមានស្នាដៃល្អក្នុងការបំពេញភារកិច្ចបម្រើជាតិមាតុភូមិ កន្លងមក ដូចមានរាយនាមខាងក្រោម៖

**ក-មេដាយមាសការងារ**

១- លោក **ខូច អ៊ីរ** មេឃុំកោះពីរ
២- លោក **ចឹម គីមសាន** នាយប៉ុស្តិ៍នគបាលរដ្ឋបាលឃុំកោះពីរ
៣- លោក **គួ សាទីម** ប្រធានការិយាល័យភូមិបាលស្រុកក្រូចឆ្មារ

**ខ-មេដាយប្រាក់ការងារ**

១- លោក **ឡុង សុខ** ក្រុមប្រឹក្សាឃុំកោះពីរ
២- លោក **អ៊ុំ អ៊ឹមសេង** ក្រុមប្រឹក្សាឃុំកោះពីរ
៣- លោក **ឯក ថុន** ក្រុមប្រឹក្សាឃុំកោះពីរ
៤- លោក **គាត សយ** មេភូមិជួរកណ្តាល(ចូលនិវត្តន៍)
៥- លោក **កយ សុខ** មេភូមិកោះត្រែង
៦- លោក **អាន អិត** មេភូមិបីពៃ
៧- លោក **យ៉ុន ស៊ាងហេង** មេភូមិម៉ឺនទង់
៨- លោក **ឈុន ហៃ** មេភូមិជួរកណ្តាល
៩- កញ្ញា **អាត ចាន់ថា** ស្មៀនឃុំកោះពីរ

គ-មេជាយសំរឹទ្ធការងារ

| | | |
|---|---|---|
| ១- | លោក **អ៊ីរ តាន់ហេង** | អនុប្រធានភូមិបីពៃ |
| ២- | លោក **ឈង រាង** | អនុប្រធានភូមិកោះត្រែង |
| ៣- | លោកស្រី **ផាង សុខខេង** | អនុប្រធានភូមិជ្ជូរកណ្តាល |
| ៤- | លោក **រ ចន្ថា** | អនុប្រធានភូមិម៉ុននង់ |
| ៥- | លោក **ង៉ូវ ប៊ី** | សមាជិកភូមិបីពៃ |
| ៦- | លោកស្រី **ផ្លុញ ស្រេន** | សមាជិកភូមិជ្ជូរកណ្តាល |
| ៧- | លោកស្រី **ម៉េង ឆារ៉ា** | សមាជិកភូមិត្រែង |
| ៨- | លោកស្រី **សាំង ខុន** | សមាជិកភូមិម៉ុននង់ |

**មាត្រា ២.**_ រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ និងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

*ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១១ ខែ កុម្ភៈ ឆ្នាំ ២០១៦*

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល:**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា១ និងមាត្រា២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ: ១៥៧ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពីការជូនមេដាយស្ថាបនាជាតិ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា ១.–**

ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ប្រគេន និងផ្តល់ជូនសប្បុរសជននៅក្នុង និងក្រៅប្រទេសចំនួន ៣០រូប ដែលបានបរិច្ចាគធនធានផ្ទាល់ខ្លួនជួយកសាង ព្រះវិហារ ឧបដ្ឋានសាលា បល្ល័ង្កព្រះពុទ្ធរូប អណ្តូងទឹក វច្ចកុដិ និងសមិទ្ធផលនានាជាច្រើនទៀត នៅ**វត្តថ្នា** និង**វត្តព្រៃកពក** ស្ថិតនៅក្នុងស្រុករំដួល ខេត្តស្វាយរៀង ដែលមានរាយព្រះនាម និងនាមដូចខាងក្រោម :

| | | | | |
|---|---|---|---|---|
| ១-ព្រះតេជគុណ | **មាស** | **សាខន** | គង់នៅរាជធានីភ្នំពេញ | បច្ច័យចំនួន ១៤.៦៦៥ ដុល្លារ |
| ២-ព្រះតេជគុណ | **យឹម** | **សារិន** | គង់នៅខេត្តស្វាយរៀង | បច្ច័យចំនួន ១៣.៧៥៥ ដុល្លារ |
| ៣-ព្រះតេជគុណ | **គង់** | **យ៉ាន** | ព្រះចៅអធិការវត្តព្រៃកពក | បច្ច័យចំនួន ១០.១០៥ ដុល្លារ |
| ៤-លោក | **ឌិត្យ** | **ស៊ីថា** | សប្បុរសជននៅខេត្តស្វាយរៀង | ថវិកាចំនួន ១៣.៣២៥ ដុល្លារ |
| ៥-លោក | **អេង** | **សារី** | សប្បុរសជនខ្មែររស់នៅសហរដ្ឋអាមេរិក | ថវិកាចំនួន ១២.២៧៥ ដុល្លារ |
| ៦-លោកស្រី | **ខួន** | **ផាស៊ូរី** | សប្បុរសជនខ្មែររស់នៅប្រទេសបារាំង | ថវិកាចំនួន ១១.១៥០ ដុល្លារ |
| ៧-លោកគ្រូអាចារ្យ | **ខៅ** | **ទី** | សប្បុរសជននៅខេត្តកណ្តាល | ថវិកាចំនួន ១១.១៥០ ដុល្លារ |
| ៨-ឧបាសក | **នេត** | **ស្រេង** | សប្បុរសជននៅខេត្តកណ្តាល | ថវិកាចំនួន ១១.០៤២ ដុល្លារ |
| ៩-ឧបាសក | **ភន** | **ត្នូង** | សប្បុរសជននៅខេត្តកណ្តាល | ថវិកាចំនួន ១១.០២៥ ដុល្លារ |
| ១០-លោក | **ញឹម** | **ហុន** | សប្បុរសជននៅខេត្តកណ្តាល | ថវិកាចំនួន ១១.០២២ ដុល្លារ |
| ១១-លោក | **សុខ** | **សារ៉ុន** | សប្បុរសជននៅខេត្តស្វាយរៀង | ថវិកាចំនួន ១១.០២០ ដុល្លារ |

| | | | | |
|---|---|---|---|---|
| ១២-លោក | **អ៊ុម** | **សំអឿន** | សប្បុរសជននៅរាជធានីភ្នំពេញ | ថវិកាចំនួន ១១.០១២ ដុល្លារ |
| ១៣-លោក | **ម៉ៅ** | **សាមឿន** | សប្បុរសជននៅខេត្តស្វាយរៀង | ថវិកាចំនួន ១១.០១០ ដុល្លារ |
| ១៤-ឯកឧត្តម | **សៅ** | **សុខា** | សប្បុរសជននៅរាជធានីភ្នំពេញ | ថវិកាចំនួន ១០.៧៥៥ ដុល្លារ |
| ១៥-លោកជំទាវ | **មាស** | **សន** | សប្បុរសជននៅខេត្តសៀមរាប | ថវិកាចំនួន ១០.៥៨៥ ដុល្លារ |
| ១៦-ឯកឧត្តម | **ពៅ** | **ហេង** | សប្បុរសជននៅខេត្តសៀមរាប | ថវិកាចំនួន ១០.៤៧៥ ដុល្លារ |
| ១៧-ឯកឧត្តម | **ស៊ុន** | **គីមថៃ** | សប្បុរសជននៅខេត្តសៀមរាប | ថវិកាចំនួន ១០.៤៥០ ដុល្លារ |
| ១៨-ឯកឧត្តម | **អៀម** | **ប៊ុណ្ណា** | សប្បុរសជននៅខេត្តសៀមរាប | ថវិកាចំនួន ១០.៤២៥ ដុល្លារ |
| ១៩-ឯកឧត្តម | **នាង** | **ឃីម** | សប្បុរសជននៅខេត្តឧត្តរមានជ័យ | ថវិកាចំនួន ១០.៣៩០ ដុល្លារ |
| ២០-ឯកឧត្តម | **ប៉ែន** | **វ៉ិយ** | សប្បុរសជននៅខេត្តឧត្តរមានជ័យ | ថវិកាចំនួន ១០.២៨០ ដុល្លារ |
| ២១-លោក | **ជា** | **សុគំគ្រូ** | សប្បុរសជននៅខេត្តសៀមរាប | ថវិកាចំនួន ១០.២៧៥ ដុល្លារ |
| ២២-លោក | **ម៉ុក** | **សុវណ្ណា** | សប្បុរសជននៅខេត្តឧត្តរមានជ័យ | ថវិកាចំនួន ១០.២៦០ ដុល្លារ |
| ២៣-លោក | **មាស** | **ស៊ី** | សប្បុរសជននៅខេត្តឧត្តរមានជ័យ | ថវិកាចំនួន ១០.២៦០ ដុល្លារ |
| ២៤-ឯកឧត្តម | **សៅ** | **សេរីមុនី** | សប្បុរសជននៅរាធានីភ្នំពេញ | ថវិកាចំនួន ១០.២៣០ ដុល្លារ |
| ២៥-លោក | **ឯក** | **សាធាន** | សប្បុរសជននៅខេត្តឧត្តរមានជ័យ | ថវិកាចំនួន ១០.២២៥ ដុល្លារ |
| ២៦-លោក | **ជា** | **សុផល** | សប្បុរសជននៅខេត្តសៀមរាប | ថវិកាចំនួន ១០.២០០ ដុល្លារ |
| ២៧-លោក | **ឃ្លាំង** | **សាយ** | សប្បុរសជននៅខេត្តកំពង់ធំ | ថវិកាចំនួន ១០.១៤០ ដុល្លារ |
| ២៨-លោក | **សោម** | **បុប្ផារ័ត្ន** | សប្បុរសជននៅខេត្តព្រះវិហារ | ថវិកាចំនួន ១០.០១៤ ដុល្លារ |
| ២៩-ឧបាសិកា | **សេក** | **សាវ៉ុន** | សប្បុរសជននៅខេត្តកណ្ដាល | ថវិកាចំនួន ១០.០០០ ដុល្លារ |
| ៣០-ព្រឹទ្ធាចារ្យ | **រាជ** | **មិត** | សប្បុរសជននៅខេត្តស្វាយរៀង | ថវិកាចំនួន ១០.០០០ ដុល្លារ |

**មាត្រា ២.—**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ និង សាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ១២ ខែ កុម្ភៈ ឆ្នាំ ២០១៦

**នាយករដ្ឋមន្ត្រី**

**សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

កន្លែងទទួល :

- ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្ដេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា២
-រាជកិច្ច
- ឯកសារ កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
លេខៈ ១៩០ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពីការជូនមេដាយស្ថាបនាជាតិ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

មាត្រា ១.—

ត្រូវបានបំពាក់ **មេដាយស្ថាបនាជាតិ** ប្រគេន និងផ្តល់ជូនសប្បុរសជនចំនួន ២៤ រូប ដែលបានបរិច្ចាគធនធាន ដែលបានបរិច្ចាគធនធានផ្ទាល់ខ្លួនជួយកសាងសមិទ្ធផលនានាក្នុងវិស័យ ព្រះពុទ្ធសាសនា និងហេដ្ឋារចនាសម្ព័ន្ធគមនាគមន៍ នៅ **វត្តខ្លាយ** ស្ថិតនៅក្នុងឃុំរមាំងថ្កោល ស្រុកស្វាយទាប ខេត្តស្វាយរៀង ដែលមានរាយព្រះនាម និងនាមដូចខាងក្រោម :

**ក. មេដាយមាសស្ថាបនាជាតិចំនួន ០៥ គ្រឿង ផ្តល់ជូន :**

| | | | | |
|---|---|---|---|---|
| ១-លោក | **នៅ** | **សំរដ្ឋា** | សប្បុរសជននៅខេត្តសៀមរាប | ថវិកាចំនួន ១៣.០៧២ ដុល្លារ |
| ២-លោក | **នៅ** | **សំមុន្នី** | សប្បុរសជននៅរាជធានីភ្នំពេញ | ថវិកាចំនួន ១២.០០០ ដុល្លារ |
| ៣-លោក | **នៅ** | **សំទាសនា** | សប្បុរសជននៅខេត្តឧត្តរមានជ័យ | ថវិកាចំនួន ១១.៨៥០ ដុល្លារ |
| ៤-ឯកឧត្តម | **ស្រ៊ុន** | **ម៉េងលាង** | សប្បុរសជននៅខេត្តកំពង់ចាម | ថវិកាចំនួន ១១.០០០ ដុល្លារ |
| ៥-លោក | **លី** | **សាងស៊ីន** | ( Mr. LEE SANG SIN ) | សប្បុរសជនជនជាតិកូរ៉េ |

**ខ. មេដាយប្រាក់ស្ថាបនាជាតិចំនួន ០៧ គ្រឿង ផ្តល់ជូន :**

| | | | | |
|---|---|---|---|---|
| ១-លោក | **នៅ** | **សំរតនា** | សប្បុរសជននៅខេត្តសៀមរាប | ថវិកាចំនួន ៨.៦៥០ ដុល្លារ |
| ២-ឯកឧត្តម | **ផន** | **សាលីន** | សប្បុរសជននៅខេត្តបាត់ដំបង | ថវិកាចំនួន ៨.៣៧០ ដុល្លារ |

| | | | | |
|---|---|---|---|---|
| ៣-ឯកឧត្តម | **ម៉ុក សុវណ្ណ** | សប្បុរសជននៅខេត្តឧត្តរមានជ័យ | ថវិកាចំនួន | ៨.០៥៩ ដុល្លារ |
| ៤-លោក | **លី សេងហ៊ត** | សប្បុរសជននៅខេត្តសៀមរាប | ថវិកាចំនួន | ៧.៨៨០ ដុល្លារ |
| ៥-លោកជំទាវ | **ផុន ស្រីមុំ** | សប្បុរសជននៅខេត្តឧត្តរមានជ័យ | ថវិកាចំនួន | ៧.២៥៥ ដុល្លារ |
| ៦-លោក | **ធន ចំន្ទនី** | សប្បុរសជននៅខេត្តសៀមរាប | ថវិកាចំនួន | ៧.១០០ ដុល្លារ |
| ៧-លោកជំទាវ | **ឈុន សារីម** | សប្បុរសជននៅខេត្តស្វាយរៀង | ថវិកាចំនួន | ៥.៥៩៤ ដុល្លារ |

**គ. មេដាយសិរីវឌ្ឍនៈស្ថាបនាជាតិចំនួន ១២ គ្រឿង ប្រគេន និងផ្តល់ជូន :**

| | | | | |
|---|---|---|---|---|
| ១-ព្រះតេជគុណ | **អែម សារិន** | ព្រះចៅអធិការវត្តរមាំងថ្កោល | បច្ច័យចំនួន | ១.៦៥៨ ដុល្លារ |
| ២-លោកស្រី | **ម៉ែន សុន្ធរី** | សប្បុរសជននៅខេត្តរតនគិរី | ថវិកាចំនួន | ៤.០០០ ដុល្លារ |
| ៣-ឯកឧត្តម | **ជ័យ ស៊ុន** | សប្បុរសជននៅរាជធានីភ្នំពេញ | ថវិកាចំនួន | ៣.១៤៤ ដុល្លារ |
| ៤-លោក | **ត្រាប សំបូរ** | សប្បុរសជននៅរាជធានីភ្នំពេញ | ថវិកាចំនួន | ២.៥០០ ដុល្លារ |
| ៥-ឯកឧត្តម | **ឡូយ សុផាត** | សប្បុរសជននៅខេត្តក្រចេះ | ថវិកាចំនួន | ១.៥០០ ដុល្លារ |
| ៦-ឯកឧត្តម | **កែប ជុតិម៉ា** | សប្បុរសជននៅរាជធានីភ្នំពេញ | ថវិកាចំនួន | ១.៥០០ ដុល្លារ |
| ៧-លោក | **សំ សារឿន** | សប្បុរសជននៅរាជធានីភ្នំពេញ | ថវិកាចំនួន | ១.២០០ ដុល្លារ |
| ៨-លោក | **នៅ សំដារ៉ារិទ្ធ** | សប្បុរសជននៅខេត្តឧត្តរមានជ័យ | ថវិកាចំនួន | ១.១៧៣ ដុល្លារ |
| ៩-លោកអាចារ្យ | **សេក សារបូរ** | សប្បុរសជននៅខេត្តស្វាយរៀង | ថវិកាចំនួន | ១.០៥០ ដុល្លារ |
| ១០-លោក | **ច្រាជ្ញ គង់** | សប្បុរសជននៅរាជធានីភ្នំពេញ | ថវិកាចំនួន | ១.០០០ ដុល្លារ |
| ១១-ឧកញ៉ា | **កែវ សារ៉ាន** | សប្បុរសជននៅរាជធានីភ្នំពេញ | ថវិកាចំនួន | ១.០០០ ដុល្លារ |
| ១២-លោក | **ឡៀង សាខន** | សប្បុរសជននៅខេត្តឧត្តរមានជ័យ | ថវិកាចំមួន | ១.០០០ ដុល្លារ |

មាត្រា ២ .—

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ និង សាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀង១ខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

*រាជធានីភ្នំពេញ,ថ្ងៃទី ១៤ ខែ កុម្ភៈ ឆ្នាំ ២០១៦*

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

<u>កន្លែងទទួល</u> :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា២
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ  សាសនា  ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:** ១៦១ អនក្រ.តត

# អនុក្រឹត្យ
## ស្តីពីការបញ្ចប់ភារកិច្ចមន្ត្រីរាជការ

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ លេខ នស / រកត / ០៩១៣ / ៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២/ នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- បានឃើញអនុក្រឹត្យលេខ ៤៨៤ អនក្រ.បក ចុះថ្ងៃទី ២៦ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការបង្កើតខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា
- យោងតាមតម្រូវការការងារចាំបាច់

**សម្រេច**

**មាត្រា ១** : បញ្ចប់ភារកិច្ចលោក **ឆិត ជាវរិទ្ធ** ពីជំនួយការសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា មានឋានៈស្មើ អគ្គនាយករង ។

**មាត្រា ២** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រី គ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធនិងសាមីខ្លួនដូចមានចែងក្នុងមាត្រា ១ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

*រាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែ កុម្ភៈ ឆ្នាំ ២០១៦*

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល :**

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ២*
- *រាជកិច្ច*
- *ឯកសារ-កាលប្បវត្តិ*

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ ១៦៧ អនក្រ.បក

## អនុក្រឹត្យ
## ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ
## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងឧស្សាហកម្មនិងសិប្បកម្ម

## សម្រេច

**មាត្រា១.**_បំពាក់ **មេដាយមុនីសារាភ័ណ្ឌ** តាមលំដាប់ថ្នាក់ ជូនមន្ត្រីរាជការ និងសប្បុរសជន ចំនួន១៦រូប ដែលមានស្នាដៃល្អក្នុងការសាងសង់សាលាធម្មសភា និងអគារសិក្សាវិទ្យាល័យ ហ៊ុន សែន វត្តស្វាយ ស្ថិតនៅសង្កាត់សាលាកំរើក ក្រុងសៀមរាប ខេត្តសៀមរាប កន្លងមក ដូចមានរាយនាមខាងក្រោម ៖

**ក-មេដាយមុនីសារាភ័ណ្ឌ ថ្នាក់ ធិបឌិន្ទ**

| | | | |
|---|---|---|---|
| ១-ឯកឧត្តម | **ឃុត** | **ទុត្យារិទ្ធ** | អគ្គនាយករដ្ឋាករទឹកស្វយ័តសៀមរាប |
| ២-លោក | **ឡុង** | **ណារ៉ូ** | អគ្គនាយករងរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ |
| ៣-លោក | **កែវ** | **សុវណ្ណរិទ្ធ** | អគ្គនាយករងរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ |
| ៤-លោក | **ជា** | **វិសុទ្ធ** | អគ្គនាយករងរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ |
| ៥-លោក | **រស់** | **គីមលាង** | អគ្គនាយករងរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ |
| ៦-លោក | **ស៊ីរិទ្ធ** | **សុវិទ្យា** | អគ្គនាយករងរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ |
| ៧-លោក | **ចាន់** | **ពិសិដ្ឋ** | អគ្គនាយករងរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ |
| ៨-លោកស្រី | **ខិន** | **ចន្ទ្រា** | អគ្គនាយិការងរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ |
| ៩-លោក | **ចាន់** | **សេងឡា** | អគ្គនាយករងរដ្ឋាករទឹកស្វយ័តសៀមរាប |
| ១០-លោក | **ជាង** | **ចាន់នី** | អគ្គនាយករងរដ្ឋាករទឹកស្វយ័តសៀមរាប |

**ខ-មេដាយមុនីសារាភ័ណ្ឌ ថ្នាក់ អស្សឫទ្ធិ**

| | | | |
|---|---|---|---|
| ១-លោក | **សាម** | **ឡុន** | ចៅសង្កាត់សាលាកំរើក |
| ២-លោក | **ម៉ិរាប** | **ថា** | មេឃុំត្បែង |
| ៣-លោក | **តិន** | **សុវណ្ណារិទ្ធ** | នាយកវិទ្យាល័យ ហ៊ុន សែន វត្តស្វាយ |
| ៤-លោក | **ឡាច** | **ប៊ុនធឿន** | នាយកបឋមសិក្សា ហ៊ុន សែន វត្តស្វាយ |
| ៥-លោក | **វ៉ាន់** | **សុវត្ថារ៉ា** | នាយករងវិទ្យាល័យ ហ៊ុន សែន វត្តស្វាយ |
| ៦-លោកស្រី | **សុខ** | **ហ៊ុច** | នាយិការងវិទ្យាល័យ ហ៊ុន សែន វត្តស្វាយ |

**មាត្រា២.**.រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម អភិបាលនៃគណៈអភិបាលខេត្តសៀមរាប និងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

**កន្លែងទទួល:**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា១ និងមាត្រា២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែ [illegible] ឆ្នាំ ២០១៦

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
លេខ: ១៧៣ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពីការជូនមេដាយការងារ
## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
-តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងឧស្សាហកម្មនិងសិប្បកម្ម

**សម្រេច**

**មាត្រា១.** បំពាក់ **មេដាយសំរឹទ្ធការងារ** ជូនមន្ត្រីរាជការ ចំនួន០៥រូប ដែលមានស្នាដៃល្អក្នុងការចូលរួមជួយកសាងសមិទ្ធផលនានា នៅសង្កាត់សាលាកំរើក ក្រុងសៀមរាប ខេត្តសៀមរាប កន្លងមក ដូចមានរាយនាមខាងក្រោម ៖

| | | |
|---|---|---|
| ១-លោក | **អ៊ុច លាងសេង** | អនុប្រធានគណៈកម្មការទ្រទ្រង់វិទ្យាល័យហ៊ុនសែន វត្តស្វាយ |
| ២-លោក | **ធីម គួម** | សមាជិកគណៈកម្មការទ្រទ្រង់វិទ្យាល័យ ហ៊ុន សែន វត្តស្វាយ |
| ៣-លោក | **ឈុយ សារឿន** | ប្រធានភូមិវត្តស្វាយ |
| ៤-លោក | **ធី ប៊ុនរ៉ុង** | សមាជិកគណៈកម្មការទ្រទ្រង់វិទ្យាល័យ ហ៊ុន សែន វត្តស្វាយ |
| ៥-លោក | **ហឿន សំនៀង** | ស្ថាបនិកសមាគមជីវិតនៃក្តីសង្ឃឹម |

**មាត្រា២.** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងឧស្សាហកម្មនិងសិប្បកម្ម អភិបាលនៃគណៈអភិបាលខេត្តសៀមរាប និងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែ កុម្ភៈ ឆ្នាំ ២០១៦
**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល:**
-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
-ដូចមាត្រា១ និងមាត្រា២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ:១៦៤ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពីការជូនមេដាយស្ថាបនាជាតិ
## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងឧស្សាហកម្មនិងសិប្បកម្ម

### សម្រេច

**មាត្រា១.** បំពាក់ មេដាយសំរឹទ្ធស្ថាបនាជាតិ ជូនសប្បុរសជន ចំនួន០៣រូប ដែលបានចូលរួមជួយសាងសង់សាលាធម្មសភានិងអគារសិក្សាវិទ្យាល័យ ហ៊ុន សែន វត្តស្វាយ ស្ថិតនៅសង្កាត់សាលាកំរើក ក្រុងសៀមរាប ខេត្តសៀមរាប កន្លងមក ដូចមានរាយនាមខាងក្រោម ៖

| | | | |
|---|---|---|---|
| ១-លោក | **ហាន់** | **ហេង** | អាចារ្យវត្តស្វាយ |
| ២-លោក | **សេន** | **រី** | គណៈកម្មការវត្តស្វាយ |
| ៣-លោក | **អ៊ិន** | **ឌី** | គណៈកម្មការវត្តស្វាយ |

**មាត្រា២.** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងឧស្សាហកម្មនិងសិប្បកម្ម អភិបាលនៃគណៈអភិបាលខេត្តសៀមរាប និងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែ កុម្ភៈ ឆ្នាំ ២០១៦

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល:**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា១ និងមាត្រា២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ១៦៥ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការតែងតាំងមន្ត្រីរាជការ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញអនុក្រឹត្យលេខ ២៦ អនក្រ.បក ចុះថ្ងៃទី២៩ ខែមករា ឆ្នាំ២០០៩ ស្តីពីការកំណត់ចំនួនគណៈអភិបាលរាជធានី គណៈអភិបាលខេត្ត គណៈអភិបាលក្រុង គណៈអភិបាលស្រុក គណៈអភិបាលខណ្ឌ
- បានឃើញអនុក្រឹត្យលេខ ១០៩ អនក្រ.បក ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃក្រសួងមហាផ្ទៃ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា ១ :** តែងតាំងលោក **គាច លាងគា** ឋានន្តរស័ក្តិអនុមន្ត្រី ថ្នាក់លេខ២ ឲ្យកាន់មុខតំណែងជាអភិបាល នៃគណៈអភិបាលស្រុកថ្ពង នៃខេត្តកំពង់ស្ពឺ។

**មាត្រា ២ :** បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា ៣ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីគ្រប់ក្រសួង ប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនដូចមានឈ្មោះក្នុងមាត្រា១ និងមាត្រា២ខាងលើ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ២៨ ខែ កុម្ភៈ ឆ្នាំ ២០១៦

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល :**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ១៧៦ អនក្រ.បក

### អនុក្រឹត្យ
### ស្ដីពីការជូនមេដាយមុនីសារាភ័ណ្ឌ
### រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ លេខ /រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

ត្រូវបានបង្កើតរជ្ជទេយ្យបុរេប្រទានជំពូក៦០ "ការទិញ", ជំពូក៦១ "សេវាកម្ម", ជំពូក៦៥ "ឧបត្ថម្ភកធន" នៅក្រសួងមុខងារសាធារណៈ សម្រាប់មុខសញ្ញាចំណាយដូចមានចែងក្នុងប្រការ៥ថ្មី នៃប្រកាសលេខ ៨២៩ សហវ.ប្រក ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១៥ ស្តីពីការកែសម្រួលប្រការ ៤ ប្រការ ៥ ប្រការ ១៤ និងប្រការ ១៧នៃប្រកាសលេខ ១៩៣៧ សហវ.ប្រក ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៤ ស្តីពីនីតិវិធីចំណាយតាមរជ្ជទេយ្យបុរេប្រទាន សម្រាប់រដ្ឋបាលថ្នាក់ជាតិ ។

តារាងឧបសម្ព័ន្ធរជ្ជទេយ្យបុរេប្រទាន ត្រូវបានកំណត់ជាឧបសម្ព័ន្ធ នៃប្រកាសនេះ ។

**ប្រការ២.-**

ចំនួនទឹកប្រាក់មួយជុំបង្វិល នៃរជ្ជទេយ្យបុរេប្រទាន ត្រូវកំណត់ដូចក្នុងតារាងឧបសម្ព័ន្ធរជ្ជទេយ្យបុរេប្រទាន ។

**ប្រការ៣.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសអន្តរក្រសួងនេះ ត្រូវទុកជានិរាករណ៍ ។

**ប្រការ៤.-**

នាយកខុទ្ទកាល័យ អគ្គនាយកនៃអគ្គនាយកដ្ឋានរតនាគារជាតិ អគ្គនាយកនៃអគ្គនាយកដ្ឋានថវិកា អគ្គនាយកនៃអគ្គនាយកដ្ឋានទទួលបន្ទុករដ្ឋបាល និងហិរញ្ញវត្ថុរបស់ក្រសួងមុខងារសាធារណៈ ប្រធានគ្រប់អង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងមុខងារសាធារណៈត្រូវទទួលបន្ទុកអនុវត្តប្រកាសអន្តរក្រសួងនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៩ ខែ [illegible] ឆ្នាំ២០១៦

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**បណ្ឌិត. អូន ព័ន្ធមុនីរ័ត្ន**

**រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ**

**ពេជ្រ ប៊ុនធិន**

**កន្លែងទទួល៖**

-ទីស្តីការគណៈរដ្ឋមន្ត្រី
-ក្រសួងមុខងារសាធារណៈ
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
-សាលារាជធានី ខេត្ត
-ដូចប្រការ៤
-រាជកិច្ច
-ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
៚៙✣៙៚

ក្រសួងមុខងារសាធារណៈ
៚៙✣៙៚

## តារាងឧបសម្ព័ន្ធរដ្ឋទេយ្យបុរេប្រទានថវិកាមិនមែនកម្មវិធីឆ្នាំ២០១៦ របស់ក្រសួងមុខងារសាធារណៈ

| ជំពូក | គណនី | អនុគណនី | បរិយាយ | ច្បាប់ហិរញ្ញវត្ថុ ឆ្នាំ២០១៦ | ឥណទាន ដែលជ្រើសរើស | ឥណទាន រដ្ឋទេយ្យបុរេប្រទាន | ឥណទាន ខុទាត់ធម្មតា | ឥណទាន ០១ដុំបង្វិល រដ្ឋទេយ្យបុរេប្រទាន | ភាគរយ |
|---|---|---|---|---|---|---|---|---|---|
| | | | | ១ | ២ | ៣ | ៤=២-៣ | ៥=៣/៦ដុំ | ៦=៣/២ |
| | | | **សរុបរួម** | 17,942,000,000 | 14,557,000,000 | 2,162,538,000 | 12,394,462,000 | 360,423,000 | 14.9% |
| 60 | | | **ការទិញ** | 4,029,000,000 | 3,384,000,000 | 512,800,000 | 2,871,200,000 | 85,466,667 | 15.2% |
| | 6001 | | សម្ភារៈផ្គត់ផ្គង់ថែទាំ | 778,000,000 | 778,000,000 | 52,200,000 | 725,800,000 | 8,700,000 | 31.4% |
| | | 60011 | សម្ភារៈផ្គត់ផ្គង់សំអាត និងអនាម័យ | 78,000,000 | 78,000,000 | 21,000,000 | 57,000,000 | 3,500,000 | 26.9% |
| | | 60015 | ប្រេងឥន្ទនៈ និងប្រេងរំអិល | 700,000,000 | 700,000,000 | 31,200,000 | 668,800,000 | 5,200,000 | 4.5% |
| | 6002 | | សម្ភារៈផ្គត់ផ្គង់ផ្នែករដ្ឋបាល | 1,146,000,000 | 1,146,000,000 | 262,000,000 | 884,000,000 | 43,666,667 | 22.9% |
| | | 60021 | សម្ភារៈការិយាល័យ និងបោះពុម្ព | 1,100,000,000 | 1,100,000,000 | 216,000,000 | 884,000,000 | 36,000,000 | 19.6% |
| | | 60022 | សៀវភៅមើល និងឯកសារ | 22,000,000 | 22,000,000 | 22,000,000 | - | 3,666,667 | 100.0% |
| | | 60028 | សម្ភារៈផ្គត់ផ្គង់ផ្នែករដ្ឋបាលផ្សេងៗ | 24,000,000 | 24,000,000 | 24,000,000 | - | 4,000,000 | 100.0% |
| | 6004 | | សំលៀកបំពាក់ និងការតុបតែង | 60,000,000 | 60,000,000 | 7,200,000 | 52,800,000 | 1,200,000 | 12.0% |
| | | 60041 | ឯកសណ្ឋាន | 60,000,000 | 60,000,000 | 7,200,000 | 52,800,000 | 1,200,000 | 12.0% |
| | 6005 | | សម្ភារៈតូចតាច សង្ហារឹម និងសម្ភារៈបរិក្ខារ | 1,400,000,000 | 1,400,000,000 | 191,400,000 | 1,208,600,000 | 31,900,000 | 13.7% |
| | | 60051 | សម្ភារៈ និងបរិក្ខារបច្ចេកទេស | 1,000,000,000 | 1,000,000,000 | 141,000,000 | 859,000,000 | 23,500,000 | 14.1% |
| | | 60052 | សង្ហារឹម | 250,000,000 | 250,000,000 | 28,800,000 | 221,200,000 | 4,800,000 | 11.5% |
| | | 60053 | សម្ភារៈប្រើប្រាស់ | 150,000,000 | 150,000,000 | 21,600,000 | 128,400,000 | 3,600,000 | 14.4% |
| | | 60054 | សម្ភារៈ និងឧបករណ៍ដឹកជញ្ជូន | - | - | - | - | - | 0.0% |
| | 6006 | | ថាមពល និងទឹក | 645,000,000 | - | - | - | - | 0.0% |
| | | 60061 | អគ្គិសនី | 615,000,000 | - | - | - | - | 0.0% |
| | | 60062 | ទឹក | 30,000,000 | - | - | - | - | 0.0% |
| 61 | | | **សេវាកម្ម** | 6,000,000,000 | 3,260,000,000 | 491,738,000 | 2,768,262,000 | 81,956,333 | 15.1% |
| | 6102 | | ការជួលមធ្យោបាយដឹកជញ្ជូន | 115,200,000 | 115,200,000 | 63,000,000 | 52,200,000 | 10,500,000 | 54.7% |
| | 6105 | | ការថែទាំ និងជួសជុល | 2,007,000,000 | 2,007,000,000 | 138,600,000 | 1,868,400,000 | 23,100,000 | 6.9% |
| | | 61052 | ការថែទាំ ជួសជុលអគារផ្សេងៗ និងប្រាសាទ | 1,750,000,000 | 1,750,000,000 | 31,800,000 | 1,718,200,000 | 5,300,000 | 1.8% |
| | | 61054 | ការថែទាំបណ្តាញផ្សេងៗ | 103,000,000 | 103,000,000 | 13,200,000 | 89,800,000 | 2,200,000 | 12.8% |
| | | 61056 | ការថែទាំនិងជួសជុលមធ្យោបាយដឹកជញ្ជូន | 60,000,000 | 60,000,000 | 30,000,000 | 30,000,000 | 5,000,000 | 50.0% |
| | | 61057 | ការថែទាំនិងជួសជុលសម្ភារៈ និងឧបករណ៍ | 54,000,000 | 54,000,000 | 54,000,000 | - | 9,000,000 | 100.0% |
| | | 61058 | ការថែទាំ និងជួសជុលផ្សេងៗ | 40,000,000 | 40,000,000 | 9,600,000 | 30,400,000 | 1,600,000 | 24.0% |
| | 6110 | | ទំនាក់ទំនងសាធារណៈនិងផ្សព្វផ្សាយ | 883,600,000 | 883,600,000 | 206,300,000 | 677,300,000 | 34,383,333 | 23.3% |
| | | 61101 | សោហ៊ុយទទួលភ្ញៀវជាតិ | 31,700,000 | 31,700,000 | 31,700,000 | - | 5,283,333 | 100.0% |
| | | 61102 | សោហ៊ុយទទួលភ្ញៀវបរទេស | 50,400,000 | 50,400,000 | 50,400,000 | - | 8,400,000 | 100.0% |
| | | 61103 | ប្រជុំ សិក្ខាសាលា និងសន្និសីទ | 509,400,000 | 509,400,000 | 39,000,000 | 470,400,000 | 6,500,000 | 7.7% |
| | | 61104 | ចំណាយរៀបចំពិធីបុណ្យ | 154,100,000 | 154,100,000 | 19,200,000 | 134,900,000 | 3,200,000 | 12.5% |
| | | 61105 | ចំណាយសម្រាប់វត្ថុអនុស្សាវរីយ៍ នៅក្នុងនិង | 18,000,000 | 18,000,000 | 18,000,000 | - | 3,000,000 | 100.0% |

| ជំពូក | គណនី | អនុគណនី | បរិយាយ | ច្បាប់ហិរញ្ញវត្ថុ ឆ្នាំ២០១៦ | ឥណទាន ដែលជ្រើសរើស | ឥណទាន រដ្ឋទេយ្យបុរេប្រទាន | ឥណទាន ទូទាត់ធម្មតា | ឥណទាន ០១ដុំបង្វិល រដ្ឋទេយ្យបុរេប្រទាន | ភាគរយ |
|---|---|---|---|---|---|---|---|---|---|
| | | | | ១ | ២ | ៣ | ៤=២-៣ | ៥=៣/៦ដុំ | ៦=៣/២ |
| | | 61107 | ការឃោសនានិងផ្សព្វផ្សាយព័ត៌មានសាធារណៈ | 120,000,000 | 120,000,000 | 48,000,000 | 72,000,000 | 8,000,000 | 40.0% |
| | **6111** | | **ចំណាយលើការជាវសារព័ត៌មាននិងឯកសារ** | **49,000,000** | **49,000,000** | **43,200,000** | **5,800,000** | **7,200,000** | **88.2%** |
| | | 61111 | ចំណាយលើការជាវសារព័ត៌មាន | 43,200,000 | 43,200,000 | 43,200,000 | - | 7,200,000 | 100.0% |
| | | 61113 | ចំណាយលើការជាវសៀវភៅរាជកិច្ច | 5,800,000 | 5,800,000 | - | 5,800,000 | - | 0.0% |
| | **6112** | | **ចំណាយទូទាត់សោហ៊ុយក្នុងប្រទេស** | **1,540,000,000** | **-** | **-** | **-** | **-** | **0.0%** |
| | | 61121 | សោហ៊ុយដឹកជញ្ជូន | 350,000,000 | - | - | - | - | 0.0% |
| | | 61122 | សោហ៊ុយបេសកកម្ម | 200,000,000 | - | - | - | - | 0.0% |
| | | 61123 | សោហ៊ុយស្នាក់នៅ | 990,000,000 | - | - | - | - | 0.0% |
| | **6113** | | **ចំណាយទូទាត់សោហ៊ុយក្រៅប្រទេស** | **1,200,000,000** | **-** | **-** | **-** | **-** | **0.0%** |
| | | 61131 | សោហ៊ុយដឹកជញ្ជូន | 350,000,000 | - | - | - | - | 0.0% |
| | | 61132 | សោហ៊ុយបេសកកម្ម | 250,000,000 | - | - | - | - | 0.0% |
| | | 61133 | សោហ៊ុយស្នាក់នៅ | 600,000,000 | - | - | - | - | 0.0% |
| | **6114** | | **សោហ៊ុយប្រៃសណីយ៍និងទូរគមនាគមន៍** | **205,200,000** | **205,200,000** | **40,638,000** | **164,562,000** | **6,773,000** | **19.8%** |
| | | 61141 | សោហ៊ុយប្រៃសណីយ៍ | 3,000,000 | 3,000,000 | 3,000,000 | - | 500,000 | 100.0% |
| | | 61142 | សោហ៊ុយទូរគមនាគមន៍ | 202,200,000 | 202,200,000 | 37,638,000 | 164,562,000 | 6,273,000 | 18.6% |
| **65** | | | **ឧបត្ថម្ភកធន** | **7,913,000,000** | **7,913,000,000** | **1,158,000,000** | **6,755,000,000** | **193,000,000** | **14.6%** |
| | **6502** | | ឧបត្ថម្ភកធនដល់អង្គការសាធារណៈ | 5,588,500,000 | 5,588,500,000 | 570,000,000 | 5,018,500,000 | 95,000,000 | 10.2% |
| | | 65026 | ឧបត្ថម្ភកធនដល់អង្គភាពដែលមានលក្ខណៈរដ្ឋ | 5,588,500,000 | 5,588,500,000 | 570,000,000 | 5,018,500,000 | 95,000,000 | 10.2% |
| | **6503** | | ឧបត្ថម្ភកធនដល់គ្រឹះស្ថានសាធារណៈដែល | 2,324,500,000 | 2,324,500,000 | 588,000,000 | 1,736,500,000 | 98,000,000 | 25.3% |

បានឃើញ និងពិនិត្យត្រឹមត្រូវ
ថ្ងៃទី......ខែ......ឆ្នាំ......
អគ្គនាយក
**អគ្គនាយកដ្ឋានរតនាគារជាតិ**
អគ្គនាយករង

ម៉ិញ បានសុវណ្ណអាធិច្ចាសីលា

បានឃើញ និងពិនិត្យត្រឹមត្រូវ
ថ្ងៃទី......ខែ......ឆ្នាំ......
**អគ្គនាយក**
**អគ្គនាយកដ្ឋានថវិកា**

បានឃើញ និងពិនិត្យត្រឹមត្រូវ
ថ្ងៃទី......ខែ......ឆ្នាំ......
**ប្រធាននាយកដ្ឋានផែនការ ហិរញ្ញវត្ថុ និងផ្គត់ផ្គង់**

**ពេជ ស៊ូរិយា**

ថ្ងៃទី......ខែ......ឆ្នាំ......
**រដ្ឋទេយ្យករបុរេប្រទាន**

បានឃើញ និង ឯកភាព
ថ្ងៃទី......ខែ......ឆ្នាំ......
**រដ្ឋមន្ត្រី**
**ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**បណ្ឌិត. អូន ព័ន្ធមុនីរ័ត្ន**

បានឃើញ និង ឯកភាព
ថ្ងៃទី......ខែ......ឆ្នាំ......
**រដ្ឋមន្ត្រី**
**ក្រសួងមុខងារសាធារណៈ**

**ពេជ្រ ប៊ុនធិន**

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

MINISTRY OF ECONOMY AND FINANCE
ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ ១១៩ សហវ.ប្រក

រាជធានីភ្នំពេញ ថ្ងៃទី ១០ ខែ កុម្ភៈ ឆ្នាំ ២០១៦

# ប្រកាស
## ស្តីពី
## ការបង្កើតគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងកម្មវិធីកំណែទម្រង់និងទំនើបកម្មគយ

## រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៧/០១៧ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីគយ
- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញសារាចរលេខ ០៩ សរ ចុះថ្ងៃទី ០៨ ខែធ្នូ ឆ្នាំ២០១៥ ស្តីពីវិធាននិងនីតិវិធីនៃការរៀបចំ ការអនុវត្ត ការត្រួតពិនិត្យតាមដាន និងការវាយតម្លៃលើការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ
- យោងតាមសំណូមពរការងារចាំបាច់របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

**<u>សម្រេច</u>**

**ប្រការ ១ -**

បង្កើតគណៈកម្មាធិការដឹកនាំ ការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងកម្មវិធីកំណែទម្រង់និងទំនើបកម្មគយ។

**ប្រការ ២ -**

គណៈកម្មាធិការដឹកនាំ ការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងកម្មវិធីកំណែទម្រង់និងទំនើបកម្មគយ មានសមាសភាពដូចខាងក្រោម÷

| | | | |
|---|---|---|---|
| ១. | ឯកឧត្តមបណ្ឌិត **គុណ ញឹម** | អគ្គនាយក | ប្រធាន |
| ២. | បណ្ឌិត **ម៉ែន សំអាត** | អគ្គនាយករង | អនុប្រធាន |
| ៣. | លោក **ហ៊ុច គីមហេង** | អគ្គនាយករង | អនុប្រធាន |
| ៤. | លោក **ឯមឃិន ទរ:** | អគ្គនាយករង | អនុប្រធាន |
| ៥. | លោក **នួន ច័ន្ទរិទ្ធ** | អគ្គនាយករង | អនុប្រធាន |
| ៦. | លោក **ខៀវ សំអាន** | ប្រធាននាយកដ្ឋានរដ្ឋបាលនិងគ្រប់គ្រង | សមាជិកអចិន្ត្រៃយ៍ |
| ៧. | លោកស្រី **ហេង សំអូន** | ប្រធាននាយកដ្ឋានផែនការ បច្ចេកទេស និងកិច្ចការអន្តរជាតិ | សមាជិក |
| ៨. | លោក **កើត សុទ្ធារ៉ា** | ប្រធាននាយកដ្ឋានបង្ការនិងបង្ក្រាបបទល្មើស | សមាជិក |
| ៩. | លោក **ផា អេងទ៉េង** | ប្រធាននាយកដ្ឋានរបបគយ | សមាជិក |
| ១០. | លោក **ឆ បូណាទី** | ប្រធាននាយកដ្ឋានរដ្ឋាករ | សមាជិក |
| ១១. | លោក **កែវ សុខឃាង** | ប្រធាននាយកដ្ឋានគ្រប់គ្រងតំបន់រួចពន្ធ | សមាជិក |
| ១២. | លោក **គាំ ច័ន្ទកុសល** | អនុប្រធាននាយកដ្ឋានផែនការ បច្ចេកទេស និងកិច្ចការអន្តរជាតិ | សមាជិក |
| ១៣. | លោក **សុខ សុទិឡា** | អនុប្រធាននាយកដ្ឋានផែនការ បច្ចេកទេស និងកិច្ចការអន្តរជាតិ | សមាជិក |
| ១៤. | លោក **ម៉ូរ ម៉ុនណារ៉ា** | អនុប្រធាននាយកដ្ឋានផែនការ បច្ចេកទេស និងកិច្ចការអន្តរជាតិ | សមាជិក |
| ១៥. | លោក **ស្រេង សំណាង** | អនុប្រធាននាយកដ្ឋានកិច្ចការច្បាប់ សវនកម្ម និងទំនាក់ទំនងសាធារណៈ | សមាជិក |
| ១៦. | លោក **សុខ ឡូរី** | អនុប្រធាននាយកដ្ឋានរដ្ឋបាលនិងគ្រប់គ្រង | សមាជិក |
| ១៧. | លោក **ឈន ទឿន** | អនុប្រធាននាយកដ្ឋានរដ្ឋាករ | សមាជិក |
| ១៨. | លោក **អ៊ុង ជាវ៉េង** | ប្រធានការិយាល័យគ្រប់គ្រងវិនិយោគមិនមែនកាត់ដេរ | សមាជិក |
| ១៩. | លោក **ទៀន សុជាតិ** | អនុប្រធានសាខាគយនិងរដ្ឋាកររាជធានីភ្នំពេញ | សមាជិក |
| ២០. | លោក **ជា សំណាង** | ប្រធានការិយាល័យកិច្ចការអន្តរជាតិ | សមាជិក |
| ២១. | លោក **ជួន ច័ន្ទសោភា** | ប្រធានការិយាល័យស្ថិតិ និងប្រព័ន្ធព័ត៌មានវិទ្យា | សមាជិក |
| ២២. | លោក **ជា សំអុន** | ប្រធានការិយាល័យគណនេយ្យនិងហិរញ្ញវត្ថុ | លេខាធិការ |
| ២៣. | លោកស្រី **សុខ លក្ខស្មី** | អនុប្រធានការិយាល័យបច្ចេកទេសគយ | លេខាធិការ |
| ២៤. | លោកស្រី **អ៊ុក ច័ន្ទសុភាព** | អនុប្រធានការិយាល័យកិច្ចការអន្តរៈជាតិ | លេខាធិការ |

**ប្រការ ៣ -**

គណៈកម្មាធិការដឹកនាំ ការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងកម្មវិធីកំណែទម្រង់និងទំនើបកម្មគយ មានភារកិច្ចដូចតទៅ ÷

- បង្កើតក្រុមការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងការងារកំណែទម្រង់និងទំនើបកម្មគយ
- ផ្តល់មគ្គុទេសក៍លើការកសាង និងអនុម័តផែនការសកម្មភាពសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងកំណែទម្រង់និងទំនើបកម្មគយ ដោយអនុលោមតាមយុទ្ធសាស្ត្រកៀរគរប្រមូលចំណូលរយៈពេលមធ្យមរបស់រាជរដ្ឋាភិបាលកម្ពុជា និងទស្សនវិស័យរបស់អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជាលើកំណែទម្រង់និងទំនើបកម្មគយ
- សម្របសម្រួលលើការរៀបចំ និងប្តូកសុបផែនការសកម្មភាពពីគ្រប់នាយកដ្ឋាន និងបណ្តាអង្គភាពគយនិងរដ្ឋាករមូលដ្ឋាននានា ដើម្បីពិនិត្យ ផ្តល់យោបល់ ឬកែសម្រួលផែនការយុទ្ធសាស្ត្រចាំបាច់នានា ដើម្បីឆ្លើយតបនឹងកាលានុវត្តភាពនៃតម្រូវការ ដែលអាចកើតឡើងជាយថាហេតុលើការអនុវត្តការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងកំណែទម្រង់និងទំនើបកម្មគយ
- សម្របសម្រួលដើម្បីធានាសង្គតិភាពនៃការអនុវត្តផែនការសកម្មភាពសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងកំណែទម្រង់និងទំនើបកម្មគយ អនុលោមតាមយុទ្ធសាស្ត្រកៀរគរប្រមូលចំណូលរយៈពេលមធ្យមរបស់រាជរដ្ឋាភិបាលកម្ពុជា
- សហការជាមួយអ្នកជំនាញការជាតិ និងអន្តរជាតិ ដើម្បីកៀរគរជំនួយ
- កំណត់របបប្រជុំ យន្តការត្រួតពិនិត្យ និងវាយតម្លៃប្រសិទ្ធភាពការអនុវត្តផែនការសកម្មភាព
- ផ្ញើរបាយការណ៍ពីវឌ្ឍនភាពនៃការអនុវត្តជូនក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ តាមការកំណត់
- អនុវត្តការងារផ្សេងទៀត តាមការកំណត់របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

**ប្រការ ៤ -**

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍។

**ប្រការ ៥ -**

នាយកខុទ្ទកាល័យ អគ្គលេខាធិការ អគ្គនាយក ប្រធានអង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ព្រមទាំងបុគ្គលនិងស្ថាប័នពាក់ព័ន្ធផ្សេងទៀត ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

**រដ្ឋមន្ត្រី**

**ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**បណ្ឌិត អូន ព័ន្ធមុនីរ័ត្ន**

**<u>កន្លែងទទួល</u>** :
- ទីស្តីការគណៈរដ្ឋមន្ត្រី
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា
- ខុទ្ទកាល័យឯកឧត្តម/ លោកជំទាវឧបនាយករដ្ឋមន្ត្រី "ដើម្បីជូនជ្រាប"
- ដូចប្រការ ៥ "ដើម្បីអនុវត្ត"
- រាជកិច្ច
- ឯកសារ - កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ...០០៣......សហវ.....

រាជធានីភ្នំពេញ ថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០១៦

## សេចក្តីសម្រេច

## ស្តីពី

## ការតែងតាំងសមាសភាពគណៈកម្មាធិការវាយតម្លៃសមិទ្ធកម្ម និងការផ្តល់ការលើកទឹកចិត្តរបស់អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា

## រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៧/០១៧ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីគយ
- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញប្រកាសលេខ ៦១៦ សហវ.ប្រក ចុះថ្ងៃទី០៤ ខែមិថុនា ឆ្នាំ២០១៤ ស្តីពីការកំណត់គោលការណ៍ យន្តការ នីតិវិធី និងការត្រួតពិនិត្យសម្រាប់ការផ្តល់ការលើកទឹកចិត្តដោយប្រើប្រាស់ប្រាក់រង្វាន់របស់អង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- យោងតាមសំណូមពរការងារចាំបាច់របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

## សម្រេច

**ប្រការ ១ -**

ត្រូវបានតែងតាំងសមាសភាពគណៈកម្មាធិការវាយតម្លៃសមិទ្ធកម្ម និងការផ្តល់ការលើកទឹកចិត្តរបស់អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា ដែលសរសេរអក្សរកាត់ថា "គ.ស.ល.អគរ" ដូចខាងក្រោម÷

| | | |
|---|---|---|
| ១. ឯកឧត្តមបណ្ឌិត **គុណ ញឹម** | អគ្គនាយក | ប្រធាន |
| ២. លោក **ប៉ែន សំអាត** | អគ្គនាយករង | អនុប្រធាន |
| ៣. លោក **ហ៊ីវ គីមហេង** | អគ្គនាយករង | អនុប្រធាន |
| ៤. លោក **នួន ច័ន្ទរិទ្ធ** | អគ្គនាយករង | អនុប្រធាន |
| ៥. លោក **ឯមឃិន ថេរៈ** | អគ្គនាយករង | អនុប្រធាន |
| ៦. លោក **ខៀវ សំអាន** | ប្រធាននាយកដ្ឋានរដ្ឋបាលនិងគ្រប់គ្រង | សមាជិក |
| ៧. លោក **ឆ បូណាវី** | ប្រធាននាយកដ្ឋានរដ្ឋាករ | សមាជិក |
| ៨. លោក **កើត សុទ្ធារ៉ា** | ប្រធាននាយកដ្ឋានបង្ការនិងបង្ក្រាបបទល្មើស | សមាជិក |
| ៩. លោក **កែវ សុខឃាង** | ប្រធាននាយកដ្ឋានគ្រប់គ្រងតំបន់រួចពន្ធ | សមាជិក |
| ១០. លោកស្រី **ហេង សំអូន** | ប្រធាននាយកដ្ឋានផែនការ បច្ចេកទេស និងកិច្ចការអន្តរជាតិ | សមាជិក |
| ១១. លោក **ផា អេងវ៉េង** | ប្រធាននាយកដ្ឋានរបបគយ | សមាជិក |
| ១២. លោក **ស្រេង សំណាង** | អនុប្រធាននាយកដ្ឋានកិច្ចការច្បាប់ សវនកម្ម និងទំនាក់ទំនងសាធារណៈ | សមាជិក |
| ១៣. លោក **គាំ ច័ន្ទកុសល** | អនុប្រធានលេខាធិការដ្ឋាន | សមាជិក |
| ១៤. លោក **ម៉ុត មីន** | អនុប្រធាននាយកដ្ឋានរដ្ឋបាលនិងគ្រប់គ្រង | សមាជិក |
| ១៥. លោក **សុខ ទ្រី** | អនុប្រធាននាយកដ្ឋានរដ្ឋបាលនិងគ្រប់គ្រង | សមាជិក |
| ១៦. លោក **ជា សំអុន** | ប្រធានការិយាល័យគណនេយ្យនិងហិរញ្ញវត្ថុ | សមាជិក |

**ប្រការ ២ -**

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍។

**ប្រការ ៣ -**

នាយកខុទ្ទកាល័យ អគ្គលេខាធិការ អគ្គនាយក ប្រធានអង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ព្រមទាំងបុគ្គលនិងស្ថាប័នពាក់ព័ន្ធផ្សេងទៀត ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

**រដ្ឋមន្ត្រី**

**ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**បណ្ឌិត អូន ព័ន្ធមុនីរ័ត្ន**

**កន្លែងទទួល :**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា
- ខុទ្ទកាល័យសម្តេច/ឯកឧត្តម/លោកជំទាវឧបនាយករដ្ឋមន្ត្រី "ដើម្បីជូនជ្រាប"
- ដូចប្រការ ៣ "ដើម្បីអនុវត្ត"
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King

ក្រសួងឧស្សាហកម្ម និងសិប្បកម្ម
Ministry of Industry & Handicraft
លេខ : ...៧៨៧.....ឧស.ក៏ន.វ/ស្រក.១១

រាជធានីភ្នំពេញ, ថ្ងៃទី ២០ ខែ វិច្ឆិកា ឆ្នាំ២០១៥

## ប្រកាសបង្កើតរោងចក្រ

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៣/០១៨ ចុះថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០១៣ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងឧស្សាហកម្ម និងសិប្បកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៦/០១៨ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០០៦ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/១០១៤/០២៥ ចុះថ្ងៃទី២៣ ខែតុលា ឆ្នាំ២០១៤ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម
- បានឃើញអនុក្រឹត្យលេខ ៥៧៥ អនក្រ.បក ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម
- បានឃើញសំណើសុំប្តូរប្រកាសបង្កើតរោងចក្រ របស់ក្រុមហ៊ុន យីវ ហ្វៃ តែកឃីង (ខេមបូឌា) លីមីធីត ចុះថ្ងៃទី០៣ ខែសីហា ឆ្នាំ២០១៥។

## សម្រេច

**ប្រការ១៖** អនុញ្ញាតឲ្យក្រុមហ៊ុន យីវ ហ្វៃ តែកឃីង (ខេមបូឌា) លីមីធីត (YIU FAI PACKING (CAMBODIA) LIMITED.) តំណាងដោយ លោក HUNG KA LUNG បង្កើតរោងចក្រ ផលិតថង់ប្លាស្ទិកគ្រប់ប្រភេទ ដែលមានទីតាំងស្ថិតនៅ ផ្លូវលំ ភូមិកាកាប សង្កាត់កាកាប ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ។

| ឈ្មោះផលិតផល | លេខកូដចំណាត់ថ្នាក់ឧស្សាហកម្ម ISIC Rev.4 Code |
|---|---|
| ថង់ប្លាស្ទិក | ២២២០ |

៤៥ មហាវិថីព្រះនរោត្តម ខណ្ឌដូនពេញ ភ្នំពេញ ទូរស័ព្ទ : (៨៥៥)-២៣-២១១១៤១ . ទូរសារ : (៨៥៥)-២៣-៤២៨២៦៣
45 Preah Norodom Boulevard, Khan Daun Penh, Phnom Penh, Phone : 855-23-211141 , Fax: 855-23-428263

**ប្រការ២៖** ម្ចាស់រោងចក្រ ត្រូវលើកផ្លាកឈ្មោះរោងចក្រដូចមានចែងក្នុងមាត្រា១៨ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងដូចបានកំណត់ដោយឡែកនៅក្នុងសេចក្តីណែនាំស្តីពីការដាក់ឈ្មោះរោងចក្រ និងសិប្បកម្ម។

**ផ្លាកឈ្មោះរោងចក្រ** ៖ "រោងចក្រផលិតថង់ប្លាស្ទិកគ្រប់ប្រភេទ យីវ ហៃ តែកឃីង (ខេមបូឌា) លីមីធីត"

**ប្រការ៣៖** ការរៀបចំគ្រប់ផ្នែកក្នុងរោងចក្រ ត្រូវអនុលោមតាមមាត្រា៤នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ស្របទៅតាមប្លង់គ្រឿងចក្រ-គ្រឿងម៉ាស៊ីន ដែលបានតម្កល់នៅក្រសួងឧស្សាហកម្ម និងសិប្បកម្ម និងបទបញ្ញត្តិបច្ចេកទេសដោយឡែករបស់ក្រសួង។

**ប្រការ៤៖** មុនចាប់ផ្តើមដំណើរការរោងចក្រ ម្ចាស់រោងចក្រត្រូវជូនដំណឹងឲ្យបានមុនរយៈពេល១៥ថ្ងៃ យ៉ាងតិច និងធ្វើការស្នើសុំវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ដែលមានសុពលភាព០៣ឆ្នាំ ពីក្រសួងឧស្សាហកម្ម និងសិប្បកម្ម។

**ប្រការ៥៖** ម្ចាស់រោងចក្រ ត្រូវតាំងបង្ហាញប្រកាសបង្កើតរោងចក្រ វិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ និងលិខិតអនុញ្ញាតទាំងឡាយ ជាចំហ នៅកន្លែងសមស្របណាមួយ ដែលងាយមើលឃើញក្នុងរោងចក្ររបស់ខ្លួន ស្របតាមមាត្រា១៦ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ៦៖** ម្ចាស់រោងចក្រ ត្រូវដាក់ពាក្យស្នើសុំការអនុញ្ញាតពីក្រសួងឧស្សាហកម្ម និងសិប្បកម្ម លើការផ្លាស់ប្តូរទីតាំង ការពង្រីកផលិតកម្ម ការបង្កើតសាខារោងចក្រ ការប្តូរឈ្មោះរោងចក្រ ការបន្ថែមផលិតផលថ្មី និងការប្តូរម្ចាស់រោងចក្រ ស្របតាមមាត្រា១២ នៃច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងមាត្រា១៣ មាត្រា១៨ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ៧៖** ម្ចាស់រោងចក្រ ត្រូវគ្រប់គ្រងរោងចក្រដោយខ្លួនឯង។ ក្នុងករណី ប្រគល់សិទ្ធិឲ្យអ្នកដទៃគ្រប់គ្រងរោងចក្រជំនួសខ្លួន ម្ចាស់រោងចក្រត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរមកក្រសួងឧស្សាហកម្ម និងសិប្បកម្ម។ ក្នុងករណីនេះ ម្ចាស់រោងចក្រត្រូវតែទទួលខុសត្រូវលើគ្រប់សកម្មភាពនៃរោងចក្រ និងគុណភាពផលិតផលរបស់ខ្លួនចំពោះមុខច្បាប់ និងអ្នកប្រើប្រាស់ស្របតាមមាត្រា៥ នៃច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ៨៖** ម្ចាស់រោងចក្រ ត្រូវផ្តល់ឲ្យបានត្រឹមត្រូវ និងទៀងទាត់ នូវទិន្នន័យ និងរបាយការណ៍ប្រចាំខែ មកអគ្គនាយកដ្ឋានឧស្សាហកម្ម នៅសប្តាហ៍ទីមួយនៃខែបន្ទាប់ ទៅតាមទម្រង់កំណត់របស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម ស្របតាមមាត្រា១៩ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ៩៖** ម្ចាស់រោងចក្រ ត្រូវទទួលខុសត្រូវក្នុងការគ្រប់គ្រងសំណល់ឧស្សាហកម្មគ្រប់ប្រភេទ និងសុវត្ថិភាពឧស្សាហកម្ម តាមជំពូកទី៣នៃច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ១០៖** ម្ចាស់រោងចក្រ ត្រូវសហការជាមួយមន្ត្រីមានសមត្ថកិច្ចរបស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម ក្នុងគោលបំណងអនុវត្តការចុះធ្វើអធិការកិច្ច ស្របតាមមាត្រា៣៧ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ឲ្យមានប្រសិទ្ធភាពខ្ពស់។

ម្ចាស់រោងចក្រ ត្រូវរាយការណ៍មកក្រសួងឧស្សាហកម្ម និងសិប្បកម្ម ឲ្យបានទាប់រហ័សអំពីករណីប្រែប្រួល ហានិភ័យ ឬករណីប្រធានសក្តិផ្សេងៗ ដែលប៉ះពាល់ធ្ងន់ធ្ងរដល់ដំណើរការរបស់រោងចក្រ ស្របតាម មាត្រា៤១ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ១១៖** ម្ចាស់រោងចក្រ ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរមកក្រសួងឧស្សាហកម្ម និងសិប្បកម្ម រយៈពេល ០១ខែយ៉ាងតិច មុនថ្ងៃដែលខ្លួនបញ្ឈប់ដំណើរការរោងចក្រជាស្ថាពរ។ ករណី រោងចក្រផ្អាកដំណើរការ ជាប់ៗគ្នា ក្នុងរយៈពេល១២ខែ ឬមិនបានផ្តល់ទិន្នន័យ និងរបាយការណ៍ប្រចាំខែជាប់ៗគ្នារយៈពេល ០៣ខែ ត្រូវចាត់ទុកថា ជាការបញ្ឈប់ដំណើរការរោងចក្រជាស្ថាពរ ស្របតាមមាត្រា១៥ នៃច្បាប់ ស្តីពី វិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ១២៖** លក្ខខណ្ឌនានារបស់ប្រកាសនេះ អាចកែសម្រួល ឬធ្វើវិសោធនកម្មបាន អនុលោមតាមច្បាប់ ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។ ប្រកាសនេះ អាចដកហូតស្របតាមមាត្រា៣៩ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និង តាមលក្ខខណ្ឌទាំងឡាយនៃប្រកាសនេះ។

**ប្រការ១៣៖** ម្ចាស់រោងចក្រ ត្រូវអនុវត្តឲ្យបានត្រឹមត្រូវតាមច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងច្បាប់ស្តីពី វិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងលិខិតបទដ្ឋានគតិយុត្តិនានាពាក់ព័ន្ធនឹង វិស័យឧស្សាហកម្ម។ ក្នុងករណីល្មើស ត្រូវផ្តន្ទាទោសតាមច្បាប់ជាធរមាន។

**ប្រការ១៤៖** ប្រកាសលេខ ៨៤៤ ឧស.កឧ.ប្រក ចុះថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០១៤ របស់ក្រសួងឧស្សាហកម្ម និង សិប្បកម្ម ស្តីពីការបង្កើតរោងចក្រផលិតថង់ប្លាស្ទិកគ្រប់ប្រភេទ របស់ក្រុមហ៊ុន យីវ ហ្វៃ តែកយីង (ខេមបូឌា) លីមីធីត ត្រូវចាត់ទុកជានិរាករណ៍។

**ប្រការ១៥៖** អគ្គនាយកឧស្សាហកម្ម ប្រធាននាយកដ្ឋានពាក់ព័ន្ធ ប្រធានមន្ទីរឧស្សាហកម្ម និងសិប្បកម្ម រាជធានីភ្នំពេញ និងម្ចាស់រោងចក្រ ដូចមានចែងក្នុងប្រការ១ ត្រូវអនុវត្តប្រកាសនេះ តាមមុខការ រៀងៗខ្លួន។

**ប្រការ១៦៖** ប្រកាសនេះមានអានុភាពគតិយុត្តិ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

**ជ.រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម**

**រដ្ឋលេខាធិការ**

**សាត សាមី**

**ចម្លងជូន៖**

-ទីស្តីការគណៈរដ្ឋមន្ត្រី
-ក្រសួងពាណិជ្ជកម្ម
-ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
-ក្រសួងបរិស្ថាន
-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
-ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
-ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
-សាលារាជធានីភ្នំពេញ
"ដើម្បីជូនជ្រាប"
-ដូចប្រការ១៥ "ដើម្បីអនុវត្ត"
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King

ក្រសួងឧស្សាហកម្ម និងសិប្បកម្ម
Ministry of Industry & Handicraft
លេខ : ៦៤៣ ឧស.ក.ន.ប្រក-១១

រាជធានីភ្នំពេញ, ថ្ងៃទី២០ ខែ វិច្ឆិកា ឆ្នាំ២០១៥

# ប្រកាសបង្កើតរោងចក្រ

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៣/០១៨ ចុះថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០១៣ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងឧស្សាហកម្ម និងសិប្បកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៦/០១៨ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០០៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/១០១៤/០២៥ ចុះថ្ងៃទី២៣ ខែតុលា ឆ្នាំ២០១៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម
- បានឃើញអនុក្រឹត្យលេខ ៥៧៥ អនក្រ.បក ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម
- បានឃើញសំណើសុំប្តូរប្រកាសបង្កើតរោងចក្រកាត់ដេរ និងប៉ាក់សម្លៀកបំពាក់ របស់ក្រុមហ៊ុន ស៊ីដស៍ ហ្គាមេន (ខេមបូឌា)ចុះថ្ងៃទី០៥ ខែតុលា ឆ្នាំ២០១៥។

## សម្រេច

**ប្រការ១៖** អនុញ្ញាតឱ្យក្រុមហ៊ុន ស៊ីដស៍ ហ្គាមេន (ខេមបូឌា) (SEEDS GARMENT (CAMBODIA) CO., LTD.) តំណាងដោយ លោក **LAU MUN CHEE ANGELA** បង្កើតរោងចក្រ កាត់ដេរ និងប៉ាក់សម្លៀកបំពាក់ ដែលមានទីតាំងស្ថិតនៅ សួនឧស្សាហកម្មវឌ្ឍនៈ អគារ I ផ្លូវចោមចៅ ភូមិដំណាក់ធំ សង្កាត់ស្ទឹងមានជ័យ ខណ្ឌមានជ័យ រាជធានីភ្នំពេញ។

| ឈ្មោះផលិតផល | លេខកូដចំណាត់ថ្នាក់ឧស្សាហកម្ម ISIC Rev.4 Code |
| --- | --- |
| សម្លៀកបំពាក់ (កាត់ដេរ,ប៉ាក់) | ១៤១០ |

៤៥ មហាវិថីព្រះនរោត្តម ខណ្ឌដូនពេញ ភ្នំពេញ ទូរស័ព្ទ : (៨៥៥)-២៣-២១១១៤១ . ទូរសារ : (៨៥៥)-២៣-៤២៨២៦៣
45 Preah Norodom Boulevard, Khan Daun Penh, Phnom Penh, Phone : 855-23-211141 , Fax: 855-23-428263

**ប្រការ២៖** ម្ចាស់រោងចក្រ ត្រូវលើកផ្លាកឈ្មោះរោងចក្រដូចមានចែងក្នុងមាត្រា១៨ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងដូចបានកំណត់ដោយឡែកនៅក្នុងសេចក្តីណែនាំស្តីពីការដាក់ឈ្មោះរោងចក្រ និងសិប្បកម្ម។

**ផ្លាកឈ្មោះរោងចក្រ** ៖ "រោងចក្រកាត់ដេរសម្លៀកបំពាក់ ស៊ិជស៍ ហ្គាមេន (ខេមបូឌា) ខូ អិលធីឌី"

**ប្រការ៣៖** ការរៀបចំគ្រប់ផ្នែកក្នុងរោងចក្រ ត្រូវអនុលោមតាមមាត្រា៤នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ស្របទៅតាមប្លង់គ្រឿងចក្រ-គ្រឿងម៉ាស៊ីន ដែលបានតម្កល់នៅក្រសួងឧស្សាហកម្ម និងសិប្បកម្ម និងបទបញ្ញត្តិបច្ចេកទេសដោយឡែករបស់ក្រសួង។

**ប្រការ៤៖** មុនចាប់ផ្តើមដំណើរការរោងចក្រ ម្ចាស់រោងចក្រត្រូវជូនដំណឹងឱ្យបានមុនរយៈពេល១៥ថ្ងៃ យ៉ាងតិច និងធ្វើការស្នើសុំវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ដែលមានសុពលភាព០៣ឆ្នាំ ពីក្រសួងឧស្សាហកម្ម និងសិប្បកម្ម។

**ប្រការ៥៖** ម្ចាស់រោងចក្រ ត្រូវតាំងបង្ហាញប្រកាសបង្កើតរោងចក្រ វិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ និងលិខិតអនុញ្ញាតទាំងឡាយ ជាចំហ នៅកន្លែងសមស្របណាមួយ ដែលងាយមើលឃើញក្នុងរោងចក្ររបស់ខ្លួន ស្របតាមមាត្រា១៦ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ៦៖** ម្ចាស់រោងចក្រ ត្រូវដាក់ពាក្យស្នើសុំការអនុញ្ញាតពីក្រសួងឧស្សាហកម្ម និងសិប្បកម្ម លើការផ្លាស់ប្តូរទីតាំង ការពង្រីកផលិតកម្ម ការបង្កើតសាខារោងចក្រ ការប្តូរឈ្មោះរោងចក្រ ការបន្ថែមផលិតផលថ្មី និងការប្តូរម្ចាស់រោងចក្រ ស្របតាមមាត្រា១២ នៃច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងមាត្រា១៣ មាត្រា១៨ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ៧៖** ម្ចាស់រោងចក្រ ត្រូវគ្រប់គ្រងរោងចក្រដោយខ្លួនឯង។ ក្នុងករណី ប្រគល់សិទ្ធិឱ្យអ្នកដទៃគ្រប់គ្រងរោងចក្រជំនួសខ្លួន ម្ចាស់រោងចក្រត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរមកក្រសួងឧស្សាហកម្ម និងសិប្បកម្ម។ ក្នុងករណីនេះ ម្ចាស់រោងចក្រត្រូវតែទទួលខុសត្រូវលើគ្រប់សកម្មភាពនៃរោងចក្រ និងគុណភាពផលិតផលរបស់ខ្លួនចំពោះមុខច្បាប់ និងអ្នកប្រើប្រាស់ស្របតាមមាត្រា៥ នៃច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ៨៖** ម្ចាស់រោងចក្រ ត្រូវផ្តល់ឱ្យបានត្រឹមត្រូវ និងទៀងទាត់ នូវទិន្នន័យ និងរបាយការណ៍ប្រចាំខែ មកអគ្គនាយកដ្ឋានឧស្សាហកម្ម នៅសប្តាហ៍ទីមួយនៃខែបន្ទាប់ ទៅតាមទម្រង់កំណត់របស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម ស្របតាមមាត្រា១៩ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ៩៖** ម្ចាស់រោងចក្រ ត្រូវទទួលខុសត្រូវក្នុងការគ្រប់គ្រងសំណល់ឧស្សាហកម្មគ្រប់ប្រភេទ និងសុវត្ថិភាពឧស្សាហកម្ម តាមជំពូកទី៣នៃច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ១០៖** ម្ចាស់រោងចក្រ ត្រូវសហការជាមួយមន្ត្រីមានសមត្ថកិច្ចរបស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម ក្នុងគោលបំណងអនុវត្តការចុះធ្វើអធិការកិច្ច ស្របតាមមាត្រា៣៧ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ឱ្យមានប្រសិទ្ធភាពខ្ពស់។

ម្ចាស់រោងចក្រ ត្រូវរាយការណ៍មកក្រសួងឧស្សាហកម្ម និងសិប្បកម្ម ឱ្យបានទាប់ហ័សអំពីករណីប្រែប្រួលហានិភ័យ ឬករណីប្រធានសក្តិផ្សេងៗ ដែលប៉ះពាល់ធ្ងន់ធ្ងរដល់ដំណើរការរបស់រោងចក្រ ស្របតាមមាត្រា៤១ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ១១៖** ម្ចាស់រោងចក្រ ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរមកក្រសួងឧស្សាហកម្ម និងសិប្បកម្ម រយៈពេល ០១ខែយ៉ាងតិច មុនថ្ងៃដែលខ្លួនបញ្ឈប់ដំណើរការរោងចក្រជាស្ថាពរ។ ករណី រោងចក្រផ្អាកដំណើរការជាប់ៗគ្នា ក្នុងរយៈពេល១២ខែ ឬមិនបានផ្តល់ទិន្នន័យ និងរបាយការណ៍ប្រចាំខែជាប់ៗគ្នារយៈពេល ០៣ខែ ត្រូវចាត់ទុកថា ជាការបញ្ឈប់ដំណើរការរោងចក្រជាស្ថាពរ ស្របតាមមាត្រា១៥ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ១២៖** លក្ខខណ្ឌនានារបស់ប្រកាសនេះ អាចកែសម្រួល ឬធ្វើវិសោធនកម្មបាន អនុលោមតាមច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។ ប្រកាសនេះ អាចដកហូតស្របតាមមាត្រា៣៩ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និង តាមលក្ខខណ្ឌទាំងឡាយនៃប្រកាសនេះ។

**ប្រការ១៣៖** ម្ចាស់រោងចក្រ ត្រូវអនុវត្តឱ្យបានត្រឹមត្រូវតាមច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងច្បាប់ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងលិខិតបទដ្ឋានគតិយុត្តិនានាពាក់ព័ន្ធនឹងវិស័យឧស្សាហកម្ម។ ក្នុងករណីល្មើស ត្រូវផ្តន្ទាទោសតាមច្បាប់ជាធរមាន។

**ប្រការ១៤៖** ប្រកាសលេខ ៧១៥ ឧប.កឧ.ប្រក ចុះថ្ងៃទី១១ ខែសីហា ឆ្នាំ២០០៩ របស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ស្តីពីការបង្កើតរោងចក្រកាត់ដេរ និងប៉ាក់សម្លៀកបំពាក់ របស់ក្រុមហ៊ុន ស៊ិជស៍ ហ្គាមេន (ខេមបូឌា) ត្រូវចាត់ទុកជានិរាករណ៍។

**ប្រការ១៥៖** អគ្គនាយកឧស្សាហកម្ម ប្រធាននាយកដ្ឋានពាក់ព័ន្ធ ប្រធានមន្ទីរឧស្សាហកម្ម និងសិប្បកម្ម រាជធានីភ្នំពេញ និងម្ចាស់រោងចក្រ ដូចមានចែងក្នុងប្រការ១ ត្រូវអនុវត្តប្រកាសនេះ តាមមុខការ រៀងៗខ្លួន។

**ប្រការ១៦៖** ប្រកាសនេះមានអានុភាពគតិយុត្តិ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ជ.រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម
រដ្ឋលេខាធិការ

សាត សាមី

**ចម្លងជូន៖**
- -ទីស្តីការគណៈរដ្ឋមន្ត្រី
- -ក្រសួងពាណិជ្ជកម្ម
- -ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- -ក្រសួងបរិស្ថាន
- -ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- -ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- -ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- -សាលារាជធានីភ្នំពេញ "ដើម្បីជូនជ្រាប"
- -ដូចប្រការ១៥ "ដើម្បីអនុវត្ត"
- -រាជកិច្ច
- -ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King

ក្រសួងឧស្សាហកម្ម និងសិប្បកម្ម
Ministry of Industry & Handicraft
លេខ : [illegible] .១១

រាជធានីភ្នំពេញ, ថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០១៥

# ប្រកាសបង្កើតរោងចក្រ

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៣/០១៨ ចុះថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០១៣ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងឧស្សាហកម្ម និងសិប្បកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៦/០១៨ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០០៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/១០១៤/០២៥ ចុះថ្ងៃទី២៣ ខែតុលា ឆ្នាំ២០១៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម
- បានឃើញអនុក្រឹត្យលេខ ៩៧៥ អនក្រ.បក ចុះថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម
- បានឃើញសំណើសុំប្លូប្រកាសបង្កើតរោងចក្រកាត់ដេរសម្លៀកបំពាក់ របស់ក្រុមហ៊ុន រីកូតិច អ៊ិនដាសស្ទ្រៀល ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០១៥។

## សម្រេច

**ប្រការ១៖** អនុញ្ញាតឱ្យក្រុមហ៊ុន រីកូតិច អ៊ិនដាសស្ទ្រៀល (RICOTEX INDUSTRIAL CO., LTD) តំណាងដោយលោក CHOI CHI CHING បង្កើតរោងចក្រកាត់ដេរសម្លៀកបំពាក់ ដែលមានទីតាំងស្ថិតនៅ ភូមិស្វាយទាប ឃុំអង្គពពេល ស្រុកគងពិសី ខេត្តកំពង់ស្ពឺ។

| ឈ្មោះផលិតផល | លេខកូដចំណាត់ថ្នាក់ឧស្សាហកម្ម ISIC Rev.4 Code |
|---|---|
| សម្លៀកបំពាក់ | ១៤១០ |

៤៥ មហាវិថីព្រះនរោត្តម ខណ្ឌដូនពេញ ភ្នំពេញ ទូរស័ព្ទ ; (៨៥៥)-២៣-២១១១៤១ . ទូរសារ : (៨៥៥)-២៣-៤២៨២៦៣
45 Preah Norodom Boulevard, Khan Daun Penh, Phnom Penh, Phone : 855-23-211141 , Fax: 855-23-428263

**ប្រការ២៖** ម្ចាស់រោងចក្រ ត្រូវលើកផ្លាកឈ្មោះរោងចក្រដូចមានចែងក្នុងមាត្រា១៨ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងដូចបានកំណត់ដោយឡែកនៅក្នុងសេចក្តីណែនាំស្តីពីការដាក់ឈ្មោះរោងចក្រ និងសិប្បកម្ម។

**ផ្លាកឈ្មោះរោងចក្រ** ៖ "រោងចក្រកាត់ដេរសម្លៀកបំពាក់ រីកូតិច អ៊ិនដាសស្រៀល"

**ប្រការ៣៖** ការរៀបចំគ្រប់ផ្នែកក្នុងរោងចក្រ ត្រូវអនុលោមតាមមាត្រា៤នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ស្របទៅតាមប្លង់គ្រឿងចក្រ-គ្រឿងម៉ាស៊ីន ដែលបានតម្កល់នៅក្រសួងឧស្សាហកម្ម និងសិប្បកម្ម និងបទបញ្ញត្តិបច្ចេកទេសដោយឡែករបស់ក្រសួង។

**ប្រការ៤៖** មុនចាប់ផ្តើមដំណើរការរោងចក្រ ម្ចាស់រោងចក្រត្រូវជូនដំណឹងឲ្យបានមុនរយៈពេល១៥ថ្ងៃ យ៉ាងតិច និងធ្វើការស្នើសុំវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ដែលមានសុពលភាព០៣ឆ្នាំ ពីក្រសួងឧស្សាហកម្ម និងសិប្បកម្ម។

**ប្រការ៥៖** ម្ចាស់រោងចក្រ ត្រូវតាំងបង្ហាញប្រកាសបង្កើតរោងចក្រ វិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ និងលិខិតអនុញ្ញាតទាំងឡាយ ជាចំហ នៅកន្លែងសមស្របណាមួយ ដែលងាយមើលឃើញក្នុងរោងចក្ររបស់ខ្លួន ស្របតាមមាត្រា១៦ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ៦៖** ម្ចាស់រោងចក្រ ត្រូវដាក់ពាក្យស្នើសុំការអនុញ្ញាតពីក្រសួងឧស្សាហកម្ម និងសិប្បកម្ម លើការផ្លាស់ប្តូរទីតាំង ការពង្រីកផលិតកម្ម ការបង្កើតសាខារោងចក្រ ការប្តូរឈ្មោះរោងចក្រ ការបន្ថែមផលិតផលថ្មី និងការប្តូរម្ចាស់រោងចក្រ ស្របតាមមាត្រា១២ នៃច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងមាត្រា១៣ មាត្រា១៨ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ៧៖** ម្ចាស់រោងចក្រ ត្រូវគ្រប់គ្រងរោងចក្រដោយខ្លួនឯង។ ក្នុងករណី ប្រគល់សិទ្ធិឱ្យអ្នកដទៃគ្រប់គ្រងរោងចក្រជំនួសខ្លួន ម្ចាស់រោងចក្រត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរមកក្រសួងឧស្សាហកម្ម និងសិប្បកម្ម។ ក្នុងករណីនេះ ម្ចាស់រោងចក្រត្រូវតែទទួលខុសត្រូវលើគ្រប់សកម្មភាពនៃរោងចក្រ និងគុណភាពផលិតផលរបស់ខ្លួនចំពោះមុខច្បាប់ និងអ្នកប្រើប្រាស់ស្របតាមមាត្រា៥ នៃច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ៨៖** ម្ចាស់រោងចក្រ ត្រូវផ្តល់ឱ្យបានត្រឹមត្រូវ និងទៀងទាត់ នូវទិន្នន័យ និងរបាយការណ៍ប្រចាំខែ មកអគ្គនាយកដ្ឋានឧស្សាហកម្ម នៅសប្តាហ៍ទីមួយនៃខែបន្ទាប់ ទៅតាមទម្រង់កំណត់របស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម ស្របតាមមាត្រា១៩ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ៩៖** ម្ចាស់រោងចក្រ ត្រូវទទួលខុសត្រូវក្នុងការគ្រប់គ្រងសំណល់ឧស្សាហកម្មគ្រប់ប្រភេទ និងសុវត្ថិភាពឧស្សាហកម្ម តាមជំពូកទី៣នៃច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ១០៖** ម្ចាស់រោងចក្រ ត្រូវសហការជាមួយមន្ត្រីមានសមត្ថកិច្ចរបស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម ក្នុងគោលបំណងអនុវត្តការចុះធ្វើអធិការកិច្ច ស្របតាមមាត្រា៣៧ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ឱ្យមានប្រសិទ្ធភាពខ្ពស់។

ម្ចាស់រោងចក្រ ត្រូវរាយការណ៍មកក្រសួងឧស្សាហកម្ម និងសិប្បកម្ម ឱ្យបានទាន់ពេលវេលាអំពីករណីប្រែប្រួល ហានិភ័យ ឬករណីប្រធានសក្តិផ្សេងៗ ដែលប៉ះពាល់ធ្ងន់ធ្ងរដល់ដំណើរការរបស់រោងចក្រ ស្របតាមមាត្រា៤១ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ១១៖** ម្ចាស់រោងចក្រ ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរមកក្រសួងឧស្សាហកម្ម និងសិប្បកម្ម រយៈពេល ០១ខែយ៉ាងតិច មុនថ្ងៃដែលខ្លួនបញ្ឈប់ដំណើរការរោងចក្រជាស្ថាពរ។ ករណី រោងចក្រផ្អាកដំណើរការជាប់ៗគ្នា ក្នុងរយៈពេល១២ខែ ឬមិនបានផ្តល់ទិន្នន័យ និងរបាយការណ៍ប្រចាំខែជាប់ៗគ្នារយៈពេល ០៣ខែ ត្រូវចាត់ទុកថា ជាការបញ្ឈប់ដំណើរការរោងចក្រជាស្ថាពរ ស្របតាមមាត្រា១៥ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ១២៖** លក្ខខណ្ឌនានារបស់ប្រកាសនេះ អាចកែសម្រួល ឬធ្វើវិសោធនកម្មបាន អនុលោមតាមច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។ ប្រកាសនេះ អាចដកហូតស្របតាមមាត្រា៣៩ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និង តាមលក្ខខណ្ឌទាំងឡាយនៃប្រកាសនេះ។

**ប្រការ១៣៖** ម្ចាស់រោងចក្រ ត្រូវអនុវត្តឱ្យបានត្រឹមត្រូវតាមច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងច្បាប់ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងលិខិតបទដ្ឋានគតិយុត្តិនានាពាក់ព័ន្ធនឹងវិស័យឧស្សាហកម្ម។ ក្នុងករណីល្មើស ត្រូវផ្តន្ទាទោសតាមច្បាប់ជាធរមាន។

**ប្រការ១៤៖** ប្រកាសលេខ ០១៩៦ ឧស.កឧ.ប្រក.៨ ចុះថ្ងៃទី២៩ ខែសីហា ឆ្នាំ២០១៤ របស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម ស្តីពីការបង្កើតរោងចក្រកាត់ដេរសម្លៀកបំពាក់ របស់ក្រុមហ៊ុន រីកូតិច អ៊ិនដាសស្ទ្រៀល ត្រូវចាត់ទុកជានិរាករណ៍។

**ប្រការ១៥៖** អគ្គនាយកឧស្សាហកម្ម ប្រធាននាយកដ្ឋានពាក់ព័ន្ធ ប្រធានមន្ទីរឧស្សាហកម្ម និងសិប្បកម្ម ខេត្តកំពង់ស្ពឺ និងម្ចាស់រោងចក្រ ដូចមានចែងក្នុងប្រការ១ ត្រូវអនុវត្តប្រកាសនេះ តាមមុខការ រៀងៗខ្លួន។

**ប្រការ១៦៖** ប្រកាសនេះមានអានុភាពគតិយុត្តិ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

**ជ.រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម**
**រដ្ឋលេខាធិការ**

**សាត សាមី**

**ចម្លងជូន៖**
- -ទីស្តីការគណៈរដ្ឋមន្ត្រី
- -ក្រសួងពាណិជ្ជកម្ម
- -ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- -ក្រសួងបរិស្ថាន
- -ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- -ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- -ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- -សាលាខេត្តកំពង់ស្ពឺ
  "ដើម្បីជូនជ្រាប"
- -ដូចប្រការ១៥ "ដើម្បីអនុវត្ត"
- -រាជកិច្ច
- -ឯកសារ-កាលប្បវត្តិ